**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :** ៧ សរណន

# សារាចរណែនាំ
# ស្តីពី
# ការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ ២០១៩-២០២១

**១. សេចក្តីផ្តើម**

មាត្រា ៣៩ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈបានចែងថា ប្រតិទិនសម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ចែកជា ៣ ដំណាក់កាល÷ **ដំណាក់កាលទី ១** គឺការរៀបចំផែនការយុទ្ធសាស្រ្តថវិកា ចាប់ពីខែ មីនា ដល់ខែ ឧសភា, **ដំណាក់កាលទី ២** គឺការរៀបចំកញ្ចប់ថវិកា ចាប់ពីខែ មិថុនា ដល់ខែ កញ្ញា និង**ដំណាក់កាលទី ៣** គឺការអនុម័តថវិកា ចាប់ពីខែ តុលា ដល់ខែ ធ្នូ។ សម្រាប់ដំណាក់កាលទី ១ នេះ រាជរដ្ឋាភិបាល តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដាក់ចេញរួចហើយនូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចនិងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ ដើម្បីឱ្យក្រសួង-ស្ថាប័នសាមីនីមួយៗ មានមូលដ្ឋានសម្រាប់ការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ ២០១៩-២០២១ និងការលើកគម្រោងថវិកាប្រចាំឆ្នាំ ២០១៩។ នៅជំហានបន្ទាប់នៃដំណាក់កាលទី ១ នេះ រាជរដ្ឋាភិបាលត្រូវដាក់ចេញនូវសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តថវិកាឆ្នាំ ២០១៩-២០២១ ដើម្បីផ្តល់គោលការណ៍ណែនាំថ្មីៗ និងមគ្គុទ្ទេសបច្ចេកទេសគន្លឹះៗ សម្រាប់ជាជំនួយដល់គ្រប់ក្រសួង-ស្ថាប័ន ក្នុងការធ្វើបច្ចុប្បន្នភាព ផែនការយុទ្ធសាស្រ្តថវិកាដែលជាផែនការថវិការយៈពេល ០៣ ឆ្នាំរំកិល ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលស្ថិតក្រោមក្រសួង-ស្ថាប័ននីមួយៗត្រូវរៀបចំនៅដំណាក់កាលទីមួយនៃដំណើរការរៀបចំគម្រោងថវិកាប្រចាំឆ្នាំ។ ដោយឡែក ចំពោះការរៀបចំផែនការយុទ្ធសាស្រ្តថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងមានសារាចរណែនាំដោយឡែកមួយផ្សេងទៀត ស្របតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៦១១/០១១ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១១។

ផែនការយុទ្ធសាស្រ្តថវិកា គឺជាឧបករណ៍មួយដ៏សំខាន់សម្រាប់÷ (១)-ផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន និងគោលនយោបាយរបស់រាជរដ្ឋាភិបាល, (២)-បង្កើនវិចារណកម្មអាទិភាពចំណាយឱ្យកាន់តែឆ្លើយតបទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន, (៣)-ធានានិរន្តរភាពនៃការអនុវត្តកម្មវិធីរបស់ក្រសួង-ស្ថាប័ន ដើម្បីសម្រេចគោលបំណងគោលនយោបាយរបស់រាជរដ្ឋាភិបាលដែលបានដាក់ចេញ (៤)-ជាមូលដ្ឋាន

សម្រាប់ពន្យល់ និងបង្ហាញសេចក្ដីសំអាងអំពីតម្រូវការថវិកាសម្រាប់អនុវត្តគោលនយោបាយ និង (៥)-ជាមូលដ្ឋានសម្រាប់ការរៀបចំ និងវិភាជថវិកាប្រចាំឆ្នាំឱ្យចំគោលដៅអាទិភាព។ ដូច្នេះ ផែនការយុទ្ធសាស្ត្រថវិកាត្រូវតែឆ្លុះបញ្ចាំងឱ្យឃើញច្បាស់អំពីគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័នសាមីនីមួយៗ, អំពីកម្មវិធីច្បាស់លាស់, អំពីសូចនាករ និងគោលដៅសូចនាករសម្រាប់វាស់វែងលទ្ធផលនៃការអនុវត្តកម្មវិធី សមស្របនឹងទំហំថវិកា និងលទ្ធភាពថវិកាដែលមាន ដើម្បីរួមចំណែកសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ ក្រសួង-ស្ថាប័នមួយត្រូវមានផែនការយុទ្ធសាស្ត្រថវិការួមមួយដែលគ្របដណ្ដប់ទាំងថវិការដ្ឋបាលកណ្ដាល, ថវិកាមន្ទីរជំនាញរាជធានី-ខេត្ត និងថវិការបស់គ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមឱវាទក្រសួង-ស្ថាប័ននោះ។

ទន្ទឹមនេះ ផែនការយុទ្ធសាស្ត្រថវិកា គឺជាឧបករណ៍សំខាន់សម្រាប់ធ្វើសមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ព្រមទាំងរវាងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីធ្វើឱ្យផែនការយុទ្ធសាស្ត្រថវិកាមានគុណភាពកាន់តែល្អប្រសើរ ក៏ដូចជាជួយលើកកម្ពស់ប្រសិទ្ធភាពនៃការវិភាជ និងគ្រប់គ្រងថវិកាប្រចាំឆ្នាំ។ ដូចនេះ *ក្រសួង-ស្ថាប័ននីមួយៗចាំបាច់ត្រូវតែបង្កើត, ជុំរុញ និងលើកទឹកចិត្តដល់ក្រុមការងារថវិការបស់ខ្លួន ដែលមានសមាសភាពមកពីនាយកដ្ឋានថវិកា/ហិរញ្ញវត្ថុ ឬ/និងគណនេយ្យ ដែលហៅថា "អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ", នាយកដ្ឋានផែនការ, អង្គភាពថវិកា/អង្គភាពជំនាញ និងអង្គភាពគ្រប់គ្រងគម្រោង ឱ្យដំណើរការដោយសកម្ម និងប្រកបដោយការទទួលខុសត្រូវខ្ពស់។* **ក្រុមការងារថវិកា** ត្រូវខិតខំធានាឱ្យប្រាកដថា ទាំងធនធាន និងទាំងសកម្មភាពការងារទាំងអស់របស់ក្រសួង-ស្ថាប័នខ្លួន ត្រូវបានដាក់បញ្ចូល ឬឆ្លុះបញ្ចាំងនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា សំដៅធានាថាថវិកាត្រូវបានវិភាជត្រង់ទៅចំសកម្មភាព និងចំសេចក្ដីត្រូវការយ៉ាងពិតប្រាកដរបស់អង្គភាពអនុវត្តសកម្មភាពរៀងៗខ្លួន ព្រមទាំងធានាបាននូវតុល្យភាពនៃការវិភាជថវិកា ហើយឆ្លើយតបបានជាអតិបរមា ទៅនឹងគោលបំណងគោលនយោបាយ និងរវាងកម្មវិធី ដែលបានរៀបចំនៅក្នុងផែនការយុទ្ធសាស្ត្រថវិកា។

ជារួម ផែនការយុទ្ធសាស្ត្រថវិកា កំណត់ភាពជោគជ័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៣ គឺ **ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** (២០១៦-២០២០) ដែលត្រូវបានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការដោយ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦។ ម្យ៉ាងទៀត ថ្វីត្បិតការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ត្រូវបានកែលម្អជាលំដាប់ចាប់តាំងពីត្រូវបានដាក់ឱ្យអនុវត្តនៅឆ្នាំ ២០០៨ ប៉ុន្តែ គុណភាព និងប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា មិនទាន់ឈានដល់កម្រិតដែលរាជរដ្ឋាភិបាលចង់បាននៅឡើយ។ ដូច្នេះ ក្រសួង-ស្ថាប័ននីមួយៗចាំបាច់ត្រូវកែលម្អគុណភាពផែនការយុទ្ធសាស្ត្រថវិកាឱ្យកាន់តែល្អប្រសើរ ស្របតាមគោលការណ៍ណែនាំស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ព្រមទាំងស្មារតី និងលទ្ធផលនៃការចរចាថវិកាឆ្នាំ ២០១៨ កន្លងមកនេះ, និងការណែនាំបន្ថែមតាមរយៈសារាចរណែនាំប្រចាំឆ្នាំនេះ ជាពិសេសការគ្រោងវិភាជចំណាយទៅតាមវិស័យនៃចំណាយចរន្តថវិកាថ្នាក់ជាតិ ដូចមានកំណត់នៅ ក្នុងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ (ផ្នែក **២.២**) ខាងក្រោមនេះ។ *ទន្ទឹមនេះ ដើម្បីលើកកម្ពស់គុណភាពផែនការយុទ្ធសាស្ត្រថវិកាគ្រប់ក្រសួង-ស្ថាប័នចាំបាច់ត្រូវរៀបចំឱ្យមានយន្តការសម្របសម្រួលផ្ទៃក្នុងលើកិច្ចការនេះបន្ថែមទៀត ដោយកំណត់*

*ឱ្យបានច្បាស់អំពីតួនាទីរបស់អគ្គនាយកដ្ឋាន/នាយកដ្ឋានពាក់ព័ន្ធ និងតួនាទីរបស់អគ្គនាយកដ្ឋាន/នាយកដ្ឋានថវិកា/ហិរញ្ញវត្ថុ ដែលជា "អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ" ព្រមទាំងអាចដាក់ចេញជាគោលការណ៍ណែនាំផ្ទៃក្នុងស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក៏ដូចជាគោលការណ៍ណែនាំផ្ទៃក្នុងសម្រាប់ការរៀបចំថវិកាប្រចាំឆ្នាំផងដែរ ជាពិសេសសម្រាប់ក្រសួង-ស្ថាប័នដែលមិនទាន់បានបង្កើតនូវយន្តការនេះ ឬក៏បានបង្កើតរួចហើយ តែដំណើរការមិនទាន់បានរលូន ឬគ្មានប្រសិទ្ធភាព។ ដូចឆ្នាំកន្លងមកផងដែរ ក្រសួង-ស្ថាប័ននីមួយៗ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្តល់កិច្ចសហការល្អរវាងគ្នាទៅវិញទៅមក ដោយអនុញ្ញាតឱ្យ**ក្រុមការងារថវិកា**តាមក្រសួង-ស្ថាប័នសាមីមានភាពជាម្ចាស់ក្នុងការធ្វើការងារជាមួយមន្ត្រីជំនាញថវិកានៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ **ដើម្បីពិនិត្យឡើងវិញ និងកែលម្អរចនាសម្ព័ន្ធកម្មវិធី និងសូចនាករសមិទ្ធកម្ម តាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធីនីមួយៗ** ក្នុងគោលបំណង ដើម្បីបង្កើនគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក៏ដូចជាប្រសិទ្ធភាពក្នុងការរៀបចំច្បាប់ថវិកាប្រចាំឆ្នាំ។*

ទន្ទឹមគ្នានេះផងដែរ នៅក្នុងទិសដៅឆ្ពោះទៅអនុវត្តថវិកាសមិទ្ធកម្មពេញលេញនៅឆ្នាំ ២០២៥ ដូចបានកំណត់នៅក្នុងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ ២០១៨-២០២៥ សិទ្ធិអំណាចក្នុងការគ្រប់គ្រងថវិកា និងការអនុវត្តថវិកា ត្រូវបានផ្ទេរជាបណ្តើរៗពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទៅក្រសួង-ស្ថាប័នសាមី ចំណែកឯសិទ្ធិអំណាចនៃការទទួលខុសត្រូវលើការគ្រប់គ្រង និងអនុវត្តថវិកាផ្ទៃក្នុងក្រសួង-ស្ថាប័ននីមួយៗ ក៏ត្រូវផ្ទេរជាបណ្តើរៗផងដែរ ពីអង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ របស់ក្រសួង-ស្ថាប័ន ទៅអង្គភាពថវិកាផ្ទៃក្នុងក្រសួង-ស្ថាប័ន។ ក្នុងន័យនេះ គ្រប់ក្រសួង-ស្ថាប័នទាំងអស់ កាន់តែមានភាពចាំបាច់បំផុតក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយ-គុណភាព។

ក្នុងន័យនេះ ដើម្បីជួយដល់ក្រសួង-ស្ថាប័ន មានមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៩-២០២១ ឱ្យកាន់តែមានភាពជាក់ស្តែង រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង-ស្ថាប័ន ដូចខាងក្រោម÷

## ២-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និង គោលនយោបាយហិរញ្ញវត្ថុសាធារណៈ

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់ការរៀបចំសេចក្តីព្រាងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩ បានផ្តល់ទស្សនៈវិស័យទូលំទូលាយនៃការអភិវឌ្ឍសេដ្ឋកិច្ច និងកំណត់អាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រមទាំងនិន្នាការចំណូល និងចំណាយថវិកាជាតិសម្រាប់រយៈពេលមធ្យម ២០១៩-២០២១ ក៏ដូចជាផ្តល់នូវលំហថវិការួមសម្រាប់គ្រប់ក្រសួង-ស្ថាប័នធ្វើការកំណត់អាទិភាពសកម្មភាពការងារសម្រាប់រយៈពេលខ្លី និងមធ្យមរបស់ខ្លួន។ ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ក៏កំណត់ផងដែរអំពីលទ្ធភាពផ្នែកធនធាន និងអាទិភាពគោលនយោបាយចម្បងៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូចនេះអាចនិយាយបានថា នៅក្នុងដំណើរការនៃការរៀបចំផែនការថវិកា ការកំណត់ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ គឺជាយន្តការពីលើចុះក្រោម ចំណែកឯការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការពី

ក្រោមឡើងលើ។ យន្តការទាំងពីរនេះ គឺមានភាពចាំបាច់មិនអាចខ្វះបានដើម្បីធានាប្រសិទ្ធភាព និងភាពប្រាកដប្រជាអំពីលទ្ធភាពថវិកា និងការរៀបចំច្បាប់ថវិកាប្រចាំឆ្នាំ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលសូមគូសរំលេចនូវខ្លឹមសារស្នូលនៃក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានរៀបចំដូចខាងក្រោម÷

**២.១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច**

ផ្អែកលើចលនការកំណើនសេដ្ឋកិច្ចខ្ពស់របស់កម្ពុជានៅក្នុងរយៈពេល ៥ ឆ្នាំ កន្លងមកនេះ និងភាពកាន់តែល្អប្រសើរឡើងនៃស្ថានភាពសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ព្រមទាំងសកម្មភាពសេដ្ឋកិច្ចនៅតែរស់រវើកនៅដើមឆ្នាំនេះ កំណើនសេដ្ឋកិច្ចឆ្នាំ ២០១៨ ត្រូវបានព្យាករថា អាចសម្រេចបានក្នុងរង្វង់ ៧% គឺខ្ពស់ជាងការគ្រោងទុកបន្តិច ដែលនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ កំណើនសេដ្ឋកិច្ចត្រូវបានព្យាករថាអាចសម្រេចបានត្រឹមតែ ៦,៩%។ ចំពោះកំណើនសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០១៩ ខាងមុខនេះវិញ, តាមការព្យាករបឋមសេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងនៅបន្តកំណើនរឹងមាំក្នុងរង្វង់ ៧%។ កំណើននេះ ត្រូវបានគាំទ្រដោយកំណើននៃវិស័យកសិកម្មប្រមាណ ១,៨% និងកំណើនវិស័យឧស្សាហកម្មប្រមាណ ១០%, ដែលវិស័យនេះគាំទ្រដោយវិស័យកាត់ដេរ សំណង់ និងជាពិសេសវិស័យផលិតកម្មមិនមែនកាត់ដេរ ក្នុងនោះ វិស័យកាត់ដេរអាចមានកំណើនប្រមាណ ៥,១% និងវិស័យសំណង់អាចសម្រេចបានប្រមាណ ១៦,៩%, ព្រមទាំងកំណើនវិស័យសេវាកម្មដែលអាចនឹងសម្រេចបានក្នុងរង្វង់ ៧%។

អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ នៅឆ្នាំ ២០១៨ តាមការព្យាករ នឹងស្ថិតក្នុងកម្រិត ៣,៤% គឺទាបជាងការព្យាករ ដែលបានដាក់ចេញនៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ ហើយអាចនឹងថយចុះមកត្រឹម ៣,១% នៅឆ្នាំ ២០១៩។ អត្រាប្តូរប្រាក់នៅឆ្នាំ ២០១៨ និង ២០១៩ ត្រូវបានរំពឹងថានឹងមានស្ថិរភាពដែលមានតម្លៃជាមធ្យម ៤ ០៥០ រៀលក្នុង ១ ដុល្លារអាមេរិក ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ជំនឿទុកចិត្តពីសំណាក់សាធារណជនលើការប្រើប្រាស់ប្រាក់រៀល តាមរយៈការអនុវត្តវិធានការលើកកម្ពស់ប្រាក់រៀលរបស់ធនាគារជាតិនៃកម្ពុជា និងការបន្តពង្រឹងគោលនយោបាយគ្រប់គ្រងសាច់ប្រាក់ក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ។

ឱនភាពគណនីចរន្តនៅឆ្នាំ ២០១៩ តាមការព្យាករនឹងមានកម្រិត ៧,២% នៃ ផ.ស.ស. គឺមានការថយចុះបន្តិចបើធៀបនឹងឆ្នាំ ២០១៨ ដែលតាមការប៉ាន់ស្មាននឹងមានកម្រិត ៧,៤% នៃ ផ.ស.ស.។ ភាពប្រសើរឡើងនៃគណនីចរន្តនេះ ឆ្លុះបញ្ចាំងតាមរយៈភាពរួមតូចនៃឱនភាពសមតុល្យពាណិជ្ជកម្ម, ការកើនឡើងខ្ពស់នៃចំណូលដែលបានពីភ្ញៀវទេសចរអន្តរជាតិ និងកំណើននៃប្រាក់បង្វែរឯកជនពីបរទេស (Remittances)។ នៅឆ្នាំ ២០១៨ ទុនបម្រុងនឹងមានទំហំ ៩ ៤៩៤ លានដុល្លារអាមេរិក និងនៅឆ្នាំ ២០១៩ អាចកើនឡើងរហូតដល់ ១១ ០៥៩ លាន ដុល្លារអាមេរិក ដែលនឹងធានាការនាំចូលបានដល់ប្រមាណជាង ៦,៥ ខែ។

**២.២ ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ**

ក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៩ ដែលត្រូវបានរៀបចំ ដោយឈរលើមូលដ្ឋាននៃ

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចដូច បានគូសបញ្ជាក់ខាងលើ ព្រមជាមួយនឹងគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា (Fiscal Consolidation) មានគោលបំណងដូចខាងក្រោម៖

- បន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ
- ធានាអនុវត្តគោលនយោបាយដើម្បីជំរុញកំណើន ការងារ សមធម៌ និងប្រសិទ្ធភាព ដើម្បីបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន និងបែងចែកផ្លែផ្កាកំណើនប្រកបដោយសមធម៌ដល់គ្រប់ស្រទាប់វណ្ណៈនៃប្រជាជន
- បន្តធានាសម្រេចឱ្យបានកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយបរិយាប័ន្ន ចីរភាព និងធន់នឹងវិបត្តិ ព្រមទាំង ធានាបានស្ថិរភាព ក្នុងបរិការណ៍នៃអត្រាអតិផរណាអាចគ្រប់គ្រងបាន និងអត្រាប្តូរប្រាក់មានស្ថិរភាព;
- បន្តគាំទ្រការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ, ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ;
- បន្តគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥;
- បន្តគិតគូរ និងដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងកម្រិតសមស្របជូនដល់មន្ត្រីរាជការទូទៅ និងផ្តល់អាទិភាពលើការដំឡើងប្រាក់បំណាច់មុខងារជូនដល់មន្ត្រីក្នុងកម្រិតគ្រប់គ្រង និងមន្ត្រីដែលមានជំនាញខ្ពស់ ក្នុងក្របខ័ណ្ឌនៃការផ្សារភ្ជាប់ការកែទម្រង់រដ្ឋបាលសាធារណៈទៅនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ;
- ពន្លឿនការអនុវត្តឱ្យបានខ្លាំងក្លានូវវិធានការគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ដែលជា "យុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី" តាមរយៈការជំរុញវិនិយោគសាធារណៈឱ្យគ្រប់គ្រាន់លើហេដ្ឋារចនាសម្ព័ន្ធ និងការផ្តល់សេវាសាធារណៈចាំបាច់សម្រាប់គាំទ្រសកម្មភាពឧស្សាហកម្ម;
- បន្តជំរុញការអភិវឌ្ឍធនធានមនុស្ស តាមរយៈការលើកកម្ពស់គុណភាពអប់រំ, និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសទាំងកម្រិតទាប មធ្យម និងខ្ពស់ ដើម្បីផ្គត់ផ្គង់ពលកម្មជំនាញប្រកបដោយផលិតភាពឱ្យបានគ្រប់គ្រាន់ទៅតាមតម្រូវការរបស់ធុរកិច្ច;
- បន្តលើកកម្ពស់សេវាសុខាភិបាលតាមរយៈការវិនិយោគបន្ថែម ទាំងលើអគារមន្ទីរពេទ្យ, សម្ភារបរិក្ខារ និងសមត្ថភាពមន្ត្រីសុខាភិបាល;
- បន្តអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសផ្តោតសំខាន់លើការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូន, វិស័យថាមពល និងវិស័យឌីជីថល;
- បន្តជំរុញការអភិវឌ្ឍវិស័យកសិកម្ម ដោយផ្តោតលើការបង្កើនផលិតភាព, ពិពិធកម្ម, ការកែច្នៃកសិផល និងពាណិជ្ជូបនីយកម្ម;

- ពង្រឹងលំហូរថវិកា និងយន្តការគ្រប់គ្រងហានិភ័យ ដែលអាចកើតមានឡើងជាយថាហេតុ;
- ធានាអនុវត្តគោលនយោបាយពាក់ព័ន្ធនឹងការគ្រប់គ្រងបំណុលសាធារណៈប្រកបដោយប្រសិទ្ធភាព សំដៅ ធានារក្សានូវចីរភាពបំណុល; និង
- បន្តពង្រឹងស្ថាប័នជាតិ និងអភិបាលកិច្ច ដើម្បីធានាប្រសិទ្ធភាព, ស័ក្តិសិទ្ធិភាព, គណនេយ្យភាព និង តម្លាភាពនៃសេវាសាធារណៈ។

ដើម្បីសម្រេចបានតាមគោលដៅនៃក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌគោល-នយោបាយហិរញ្ញវត្ថុសាធារណៈខាងលើ រាជរដ្ឋាភិបាលបានកំណត់គោលដៅសូចនាករហិរញ្ញវត្ថុសាធារណៈ សម្រាប់ឆ្នាំ ២០១៩ ដូចខាងក្រោម÷

• ធានាកំណើនចំណូលចរន្តថវិការដ្ឋ ដើម្បីឈានទៅសម្រេចឱ្យបាន ១៩,២២% នៃ ផ.ស.ស. នៅ ២០១៩ ក្នុងនោះ គម្រោងសម្រាប់ថ្នាក់ជាតិ គឺ ១៧,៩៦% នៃផ.ស.ស. និងគម្រោងសម្រាប់ថ្នាក់ក្រោមជាតិគឺ ១,២៦% នៃ ផ.ស.ស.។ ដូចនេះ ចំណូលពីអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាគ្រោងសម្រេចឱ្យបាន ៨,២៧% នៃ ផ.ស.ស., ចំណូលពីអគ្គនាយកដ្ឋានពន្ធដារគ្រោងសម្រេចឱ្យបាន ៨,៣១% នៃ ផ.ស.ស. (ក្នុងនោះ ចំណូលពន្ធដារថ្នាក់ជាតិ គ្រោងសម្រេចឱ្យបាន ៧,០៨% នៃ ផ.ស.ស. និងចំណូលពន្ធដារថ្នាក់ក្រោមជាតិគ្រោងសម្រេចឱ្យបាន ១,២២% នៃផ.ស.ស.) និងចំណូលមិនមែនសារពើពន្ធត្រូវគ្រោងសម្រេចឱ្យបាន ២,៦៤% នៃ ផ.ស.ស.។ ឈរលើមូលដ្ឋាន នេះ ចំណូលក្នុងប្រទេសថវិការដ្ឋសម្រាប់ឆ្នាំ ២០១៩ គ្រោងសម្រេចឱ្យបាន ១៩,៤០% នៃផ.ស.ស.។

• ចំណាយសរុបថវិការដ្ឋនៅឆ្នាំ ២០១៩ នឹងកំណត់ក្នុងរង្វង់ ២៤,៤៧% នៃ ផ.ស.ស. ដែលក្នុងនោះ គម្រោងចំណាយសម្រាប់រដ្ឋបាលថ្នាក់ជាតិមាន ២៣,២១% នៃផ.ស.ស. និងគម្រោងចំណាយសម្រាប់រដ្ឋបាល ថ្នាក់ក្រោមជាតិមាន ១,៩៩% នៃ ផ.ស.ស. (ដោយគិតបញ្ចូលទាំងឧបត្ថម្ភធនដល់ថ្នាក់ក្រោមជាតិចំនួន ០,៧៣% នៃ ផ.ស.ស.)។ ចំណាយចរន្តថវិការដ្ឋត្រូវគ្រោងក្នុងកម្រិត ១៥,៩៧% នៃ ផ.ស.ស. ដែលគម្រោងចំណាយបន្ទុកបុគ្គលិក មានប្រមាណ ៤៧,៤% នៃចំណាយចរន្តថវិការដ្ឋ ឬស្មើប្រមាណ ៧,៥៦% នៃ ផ.ស.ស. ដោយផ្តល់អាទិភាពទៅលើ ការបង្កើនបៀវត្សសម្រាប់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ដើម្បីបង្កើនផលិតភាពការងារ និងពង្រឹង ការផ្តល់សេវាសាធារណៈ។ គួរគូសបញ្ជាក់ផងដែរថា តួលេខសមាមាត្រនៃចំណាយបន្ទុកបុគ្គលិកមានការថយចុះ ធៀបឆ្នាំ ២០១៨ ដោយសារថវិកាចំណាយសម្រាប់របបសន្តិសុខសង្គមរបស់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ត្រូវបានផ្លាស់ប្តូរការកត់ត្រាពីក្នុងប្រភេទចំណាយបន្ទុកបុគ្គលិក (ជំពូក ៦៤) ទៅកត់ត្រាជាចំណាយអត្ថប្រយោជន៍ សង្គម (ជំពូក ៦២) ក្នុងប្រភេទចំណាយក្រៅបន្ទុកបុគ្គលិកវិញ ដើម្បីឱ្យស្របតាមឧត្តមានុវត្តជាអន្តរជាតិ។ ទន្ទឹមនេះ ចំណាយមិនមែនបុគ្គលិកត្រូវបានគ្រោងប្រមាណ ៥២,៦% នៃចំណាយចរន្តថវិការដ្ឋ ឬស្មើនឹង ៨,៤១% នៃ ផ.ស.ស.។ ចំណាយនេះ នឹងត្រូវត្បិតត្បៀតឱ្យមានប្រសិទ្ធភាពបំផុត ព្រមទាំងតម្រង់ទៅលើសកម្មភាពកែទម្រង់ នានា និងការអនុវត្តគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាល។ ដោយឡែក ចំណាយមូលធនត្រូវបានគ្រោង ក្នុងកម្រិត ៨,៥០% នៃ ផ.ស.ស. (ការគ្រោងកើនឡើងចំនួន ១០,៨% ធៀបច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨) ក្នុង គោលដៅជួយទ្រទ្រង់ផលិតភាពក្នុងសេដ្ឋកិច្ច, អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងជំរុញកំណើនសេដ្ឋកិច្ច។

- ជារួម ចំណាយចរន្តថ្នាក់ជាតិសម្រាប់ឆ្នាំ ២០១៩ ត្រូវបានគ្រោងវិភាជទៅតាមវិស័យ ដូចខាងក្រោម÷
  - វិស័យរដ្ឋបាលទូទៅ ត្រូវបានគ្រោងប្រមាណ ១,៩៦% នៃ ផ.ស.ស. និងមានការថយចុះ ៤,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨, ដោយសារថវិកា គ.ជ.ប នឹងថយចុះវិញចាប់ពីឆ្នាំ២០១៩;
  - វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវបានគ្រោងប្រមាណ ៣,៩៣% នៃ ផ.ស.ស. និងមានកំណើន ១០,៩% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨;
  - វិស័យសង្គមកិច្ច ត្រូវបានគ្រោងប្រមាណ ៥,៧៥% នៃ ផ.ស.ស. និងមានកំណើន ១១,៥% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨; និង
  - វិស័យសេដ្ឋកិច្ច ត្រូវបានគ្រោងប្រមាណ ១,៣០% នៃ ផ.ស.ស. និងមានកំណើន ៣,៨% ធៀបនឹងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨។

• ឈរលើមូលដ្ឋានគម្រោងក្របខ័ណ្ឌចំណូលនិងចំណាយខាងលើ អតិរេកថវិកាចរន្តសម្រាប់ឆ្នាំ ២០១៩ គ្រោងសម្រេចបានស្មើនឹងប្រមាណ ៣,២៥% នៃ ផ.ស.ស. ចំណែកឯឱនភាពថវិកាសរុបត្រូវបានកំណត់ត្រឹម ៥,០៧% នៃ ផ.ស.ស.។ នៅក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈខាងលើនេះ, ថវិកាឆ្នាំ ២០១៩ មានចរិតជាការពង្រឹងវិន័យ និងប្រសិទ្ធភាពថវិកា តាមរយៈការរក្សាសមតុល្យថវិកា និងការផ្តោតកាន់តែសំខាន់លើប្រសិទ្ធភាពចំណាយទាំងកម្រិតវិភាជ និងប្រតិបត្តិការ។ (សូមពិនិត្យក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៧-២០១៩ ក្នុងឧបសម្ព័ន្ធ ២ ភ្ជាប់មកជាមួយ)។

ដើម្បីធានាបាននូវការអនុវត្តទៅតាមគោលដៅខាងលើ និងដោយផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៨, ក្រសួង-ស្ថាប័នត្រូវពង្រឹងការអនុវត្តវិធានការផ្នែកចំណូល និងផ្នែកចំណាយដូចខាងក្រោម÷

**ក. វិធានការផ្នែកចំណូល**

**ក.១-វិធានការផ្នែកចំណូលពន្ធដារ**

វិធានការគន្លឹះជាក់លាក់សម្រាប់ការអនុវត្តនៅក្នុងឆ្នាំ២០១៩ ក្នុងទិសដៅរក្សាកំណើនចំណូលពន្ធ និងឆ្លើយតបនឹងបញ្ហាប្រឈម រួមមាន÷

• *ការបន្តពង្រឹងមុខងារប្រតិបត្តិការស្នូល រួមមានការចុះបញ្ជីអ្នកជាប់ពន្ធ, ការផ្តល់សេវាអ្នកជាប់ពន្ធ, ការចាត់ចែងលិខិតប្រកាស, ការធ្វើសវនកម្ម, ការស៊ើបអង្កេត, ការប្រមូលបំណុលពន្ធ និងបណ្តឹងតវ៉ា* តាមរយៈ÷

- ការបន្តពង្រឹងការចុះបញ្ជីពន្ធដារចំពោះសហគ្រាសដែលមិនទាន់បានចុះបញ្ជីពន្ធដារ ដែលបានរកឃើញដោយការចុះអង្កេតសហគ្រាស និងផ្ទៀងផ្ទាត់ព័ត៌មានរបស់អ្នកជាប់ពន្ធជាមួយស្ថាប័នផ្សេងៗ;
- ការលើកទឹកចិត្តអ្នកជាប់ពន្ធឱ្យចុះបញ្ជីតាមប្រព័ន្ធអេឡិចត្រូនិក E-registration;
- ការបន្តផ្តល់សេវាជូនអ្នកជាប់ពន្ធធំ មធ្យម និងតូច តាមរយៈសិក្ខាសាលាផ្សព្វផ្សាយ និងពិគ្រោះយោបល់ទាក់ទងនឹងប្រព័ន្ធពន្ធដារ និងរដ្ឋបាលសារពើពន្ធ;

- ការបន្តចេញវិញ្ញាបនបត្របញ្ជាក់អំពីអនុលោមភាពពន្ធ (Tax Compliance Award Certificate) ចំពោះអ្នកជាប់ពន្ធដែលមានអនុលោមភាពពន្ធខ្ពស់;
- ការពង្រឹងការពិគ្រោះយោបល់តាមទូរស័ព្ទ (Call Center) និងការជជែកផ្ទាល់ជាមួយពន្ធដារ (Live Chat) និងបញ្ជូនទៅតាមនាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ;
- ការរៀបចំសៀវភៅណែនាំស្តីពីគោលការណ៍នៃកិច្ចព្រមព្រៀងស្តីពីការចៀសវាងការយកពន្ធត្រួតគ្នា;
- ការរៀបចំការដាក់លិខិតប្រកាស និងការបង់ប្រាក់ Online (E-Filing and E-Payment);
- ការរៀបចំបញ្ជរទទួលលិខិតប្រកាសពន្ធដោយស្វ័យប្រវត្តិ (Automatic Tax Return Kiosk) តាមគោលដៅអ្នកជាប់ពន្ធសំខាន់ៗ;
- ការបន្តពង្រឹងការវិភាគហានិភ័យរបស់អ្នកជាប់ពន្ធ ដើម្បីកសាងកម្មវិធីសវនកម្មប្រចាំឆ្នាំ ដោយកំណត់វិស័យដែលមានកម្រិតហានិភ័យខ្ពស់ ដូចជា វិស័យនាំចេញ-នាំចូល, វិស័យទេសចរណ៍, វិស័យសំណង់, វិស័យដឹកជញ្ជូន និងវិស័យដែលមានសក្តានុពលផ្សេងទៀតដល់កំណើនសេដ្ឋកិច្ច ដើម្បីធ្វើសវនកម្មប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព;
- ការបន្តជ្រើសរើសសហគ្រាសដែលមានបុគ្គលសម្ព័ន្ធ ជាអាទិភាពក្នុងការធ្វើសវនកម្មលើការផ្ទេរថ្លៃរវាងសហគ្រាស;
- ការជំរុញការអនុវត្តកាតព្វកិច្ចផ្តល់របាយការណ៍ហិរញ្ញវត្ថុ ដែលធ្វើសវនកម្មដោយស្នងការគណនេយ្យឯករាជ្យ ដើម្បីពង្រឹងការគោរពច្បាប់ និងបន្ថយបន្ទុកសវនកម្ម;
- ការបន្តបង្កើនការពិនិត្យផ្ទៀងផ្ទាត់ និងការប្រមូលទិន្នន័យព័ត៌មាន រួមមានការផ្ទៀងផ្ទាត់វិក្កយបត្រអាករលើតម្លៃបន្ថែមនិងប្រភេទពន្ធផ្សេងៗ ដើម្បីកសាងកម្មវិធីសវនកម្ម និងការកំណត់ពន្ធឡើងវិញ; និង
- អនុវត្តវិធានការពាក់ព័ន្ធដែលនឹងត្រូវបានដាក់ចេញ នៅក្នុងក្របខ័ណ្ឌគោលនយោបាយទំនើបកម្មប្រព័ន្ធពន្ធដារឆ្នាំ ២០១៩-២០២៣ ដែលផ្អែកលើគោលការណ៍អនុគ្រោះដល់កំណើន និងធានាយុត្តិធម៌, សមធម៌, សេវាល្អ, អភិបាលកិច្ចល្អ និងបង្កើនអនុលោមភាព។

- *បន្តការពង្រឹងមុខងារគាំទ្រ* តាមរយៈ÷
  - ដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រគ្រប់គ្រងធនធានមនុស្សរយៈពេល ០៥ ឆ្នាំ (២០១៩-២០២៣) និងផែនការប្រតិបត្តិធនធានមនុស្សឆ្នាំ២០១៩;
  - បន្តធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា ដោយអភិវឌ្ឍកម្មវិធីគ្រប់គ្រងការប្រមូលពន្ធតាមបច្ចេកវិទ្យាព័ត៌មាន;
  - បន្តរៀបចំសេចក្តីព្រាងច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ដើម្បីឆ្លើយតបនឹងការវិវឌ្ឍនៃស្ថានភាពសេដ្ឋកិច្ច-សង្គម រួមមាន÷ រៀបចំកែសម្រួលតារាងតម្លៃថ្មីសម្រាប់ជាមូលដ្ឋានគិតពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងតម្លៃជាមូលដ្ឋានគិតពន្ធលើអចលនទ្រព្យ, រៀបចំកែសម្រួលប្រកាសស្តីពីការប្រមូលពន្ធប្រថាប់ត្រា, រៀបចំប្រកាសស្តីពីការប្រមូលពន្ធលើមធ្យោបាយ

ដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ ២០១៩ និងសិក្សាភាពខ្វះចន្លោះនៃច្បាប់ស្តីពីសារពើពន្ធ; និង

- រៀបចំបង្កើតវិធីសាស្ត្រតាមដាន, វិភាគ, វាយតម្លៃ និងផ្តល់យោបល់លើការអនុវត្ត គោលនយោបាយពន្ធដារថ្នាក់ជាតិ, ក្នុងតំបន់ និងសកលលោក។

**ក.២-វិធានការផ្នែកចំណូលគយ និងរដ្ឋាករ**

ក្នុងទិសដៅបន្តពង្រឹងប្រភពចំណូលសំខាន់ ក៏ដូចជាឆ្លើយតបទៅនឹងបញ្ហាប្រឈមដែលនឹងអាចកើតមានក្នុងឆ្នាំ ២០១៩ វិធានការជាក់លាក់សម្រាប់ផ្នែកចំណូលគយនិងរដ្ឋាករ ដែលត្រូវអនុវត្តក្នុងឆ្នាំ ២០១៩ រួមមាន៖

- *បន្តពង្រឹងរដ្ឋបាលគយ តាមរយៈការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តនីតិវិធីគយ, ការងារបច្ចេកទេសគយ, ការអនុវត្តច្បាប់លើទំនិញនាំចូលល្មើសកម្មសិទ្ធិបញ្ញា, ការងារបង្ការនិងបង្ក្រាបអំពើរត់គេចពន្ធ, និងកិច្ចសហប្រតិបត្តិការអន្តរជាតិ៖*

- ពង្រឹងយន្តការគ្រប់គ្រងការអនុវត្តនីតិវិធីគយ តាមរយៈ៖ (១)- ការកត់ត្រានិងជម្រះបញ្ជីទំនិញនាំចូល, កិច្ចសហការផ្លាស់ប្តូរព័ត៌មានជាមួយអាជ្ញាធរកំពង់ផែ ដើម្បីកំណត់មុខសញ្ញាហានិភ័យមុនពេលទំនិញមកដល់, (២)- ការពង្រឹងបន្ថែមលើការគ្រប់គ្រងអាជីវកម្មលក់ទំនិញរួចពន្ធ ស្របតាមឧត្តមានុវត្តជាអន្តរជាតិ និង (៣)- ការដាក់ចេញនូវវិធានការជាក់លាក់ក្នុងការទារបំណុលពន្ធ និងអាករ;
- បង្កើនប្រសិទ្ធភាពលើការងារតម្លៃគិតពន្ធគយ, ការចាត់ថ្នាក់ទំនិញ និងវិធានដើមកំណើត តាមរយៈ៖ (១)- ការពិនិត្យឡើងវិញនូវការធ្វើមជ្ឈការនិងវិមជ្ឈការការងារផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយទៅអង្គភាពគយនិងរដ្ឋាករមូលដ្ឋានឱ្យកាន់តែសមស្របតាមការវិវត្តសភាពការណ៍, (២)-ការកែសម្រួលនីតិវិធីផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ, ការចាត់ថ្នាក់ទំនិញ និងវិធានដើមកំណើត, (៣)-ការកែលម្អប្រព័ន្ធទិន្នន័យគ្រប់គ្រងតាមមធ្យោបាយអេឡិចត្រូនិក, និង (៤)-ការតាមដាន និងវាយតម្លៃអនុលោមភាពការងារទាំងនេះ ឱ្យបានខ្ជាប់ខ្ជួន;
- កសាងនីតិវិធី, យន្តការចាំបាច់ និងបទប្បញ្ញត្តិពាក់ព័ន្ធបន្ថែមទៀតដើម្បី៖ (១)-បង្កើនប្រសិទ្ធភាពការងារបង្ក្រាបការជួញដូរទំនិញល្មើសកម្មសិទ្ធិបញ្ញា, (២)-អភិវឌ្ឍប្រព័ន្ធកត់ត្រាការចុះបញ្ជីទំនិញដែលជាកម្មវត្ថុការពារកម្មសិទ្ធិបញ្ញា, និង (៣)-បង្កើតយន្តការផ្លាស់ប្តូរព័ត៌មានរវាងរដ្ឋបាលគយជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងជាមួយម្ចាស់កម្មសិទ្ធិ;
- ពង្រឹងប្រសិទ្ធភាពយន្តការត្រួតពិនិត្យ និងបង្ក្រាបបទល្មើសទាំងនៅដើមទី កណ្តាលទី និងចុងទីតាមរយៈការងារស្រាវជ្រាវ, ស៊ើបអង្កេត, ទប់ស្កាត់ និងបង្ក្រាបបទល្មើសគយគ្រប់ប្រភេទ ទាំងបទល្មើសឆ្លងដែន, ចរាចរណ៍សាច់ប្រាក់ និងឧបករណ៍ហិរញ្ញវត្ថុខុសច្បាប់ និងការនាំចូលពុំស្របច្បាប់ និង/ឬហាមឃាត់ផ្សេងទៀត;
- បង្កើនកិច្ចសហប្រតិបត្តិការ, ការធ្វើសមាហរណកម្ម និងសុខដុមនីយកម្មកិច្ចការគយ ទាំងក្នុងកម្រិតតំបន់ និងសាកលលោកដើម្បី៖ (១)-ធានាប្រសិទ្ធភាពនៃការផ្លាស់ប្តូរព័ត៌មានស្ថិតិពាណិជ្ជកម្ម, (២)-

បង្ការ និងបង្ក្រាបបទល្មើសឆ្លងកាត់ព្រំដែន និងបទល្មើសគេចពន្ធ, (៣)-ពង្រឹងប្រសិទ្ធភាពគ្រប់គ្រងការអនុវត្តពន្ធអនុគ្រោះនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងក្របខ័ណ្ឌអាស៊ាន និងអាស៊ានជាមួយដៃគូ, និង (៤)- ចែករំលែកចំណេះដឹងបទពិសោធន៍; និង

- អនុវត្តវិធានការពាក់ព័ន្ធនឹងផ្នែកពន្ធគយ ដែលនឹងត្រូវដាក់ចេញនៅក្នុងក្របខ័ណ្ឌកែទម្រង់ប្រព័ន្ធពន្ធ ឆ្នាំ ២០១៩-២០២៣។

- ***បន្តការពង្រឹងមុខងារគាំទ្រ*** តាមរយៈ÷
  - ពង្រឹងកិច្ចសម្រួលពាណិជ្ជកម្ម តាមរយៈការអនុវត្តយន្តការប្រតិបត្តិករសេដ្ឋកិច្ចមានការអនុញ្ញាត, ការវាយតម្លៃធុរជន, ការពង្រីកមុខងារប្រព័ន្ធគ្រប់គ្រងហានិភ័យ, ការកែសម្រួលសមាសភាព និងការពង្រីកភាពគ្របដណ្តប់នៃប្រតិបត្តិការសវនកម្មគយក្រោយពេលបញ្ចេញទំនិញ, និងការផ្លាស់ប្តូរព័ត៌មានទាំងផ្ទៃក្នុងអង្គភាពគយ និងជាមួយស្ថាប័នពាក់ព័ន្ធ;
  - ពង្រឹងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងបច្ចេកវិទ្យាត្រួតពិនិត្យក្នុងការងារគយ តាមរយៈ÷ (១)-ការបន្តពង្រីកវិសាលភាពគ្របដណ្តប់នៃការអនុវត្តប្រព័ន្ធស្វ័យប្រវត្តិកម្មទិន្នន័យគយ (អាស៊ីគូដា), (២)-ការកែលម្អ និងបន្ថែមមុខងារគាំទ្រនីតិវិធីគយផ្សេងៗដល់ប្រព័ន្ធ, និង (៣)-ការតភ្ជាប់រវាង ប្រព័ន្ធអាស៊ីគូដាជាមួយប្រព័ន្ធស្វ័យប្រវត្តិកម្មគយផ្សេងទៀត;
  - បន្តរៀបចំអភិវឌ្ឍប្រព័ន្ធបញ្ជរតែមួយជាតិសម្រាប់ “ដំណាក់កាលទី២” គឺគ្រោងតភ្ជាប់ទៅស្ថាប័នពាក់ព័ន្ធនឹងការចេញអាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតក្នុងទម្រង់អេឡិចត្រូនិកប្រើប្រាស់សម្រាប់ការបញ្ចេញទំនិញពីគយ បន្ទាប់ពីការចូលរួមបញ្ជូន និងទទួលវិញ្ញាបនបត្របញ្ជាក់ប្រភពទំនិញក្នុងទម្រង់អេឡិចត្រូនិក (e-FORM D)។ ក្នុងដំណាក់កាលទី២នេះ ក្រសួង-ស្ថាប័នដែលអាចតភ្ជាប់ក្នុងប្រព័ន្ធបញ្ជរតែមួយជាតិ រួមមាន÷ ក្រសួងសុខាភិបាល, ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងតំបន់សេដ្ឋកិច្ចពិសេស, ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល;
  - ពង្រឹងប្រសិទ្ធភាពការប្រើប្រាស់ម៉ាស៊ីនស្កេន និងប្រព័ន្ធកាមេរ៉ាត្រួតពិនិត្យគយ តាមរយៈការបង្កើតមជ្ឈមណ្ឌលទទួលរូបភាពម៉ាស៊ីនស្កេន និងយន្តការគាំទ្រចាំបាច់ផ្សេងទៀត;
  - ជំរុញវិសាលភាពនៃការអនុវត្តនីតិវិធីឆ្លងកាត់គយ តាមរយៈការចូលរួមក្នុងសមាសភាព ក្រុមការងារថ្នាក់ជាតិ និងយន្តការគាំទ្រចាំបាច់នានា; និង
  - ពង្រឹងអភិបាលកិច្ចអង្គភាពគយ និងអភិវឌ្ឍន៍ស្ថាប័ន តាមរយៈការបណ្តុះបណ្តាល និងកែលម្អយន្តការវាយតម្លៃ, យន្តការលើកទឹកចិត្ត និងការដាក់ទណ្ឌកម្មដល់មន្ត្រីគយ និងបុគ្គលពាក់ព័ន្ធ។

**ក.៣- វិធានការផ្នែកចំណូលមិនមែនសារពើពន្ធ**

ដើម្បីពង្រឹងប្រភពចំណូលសំខាន់ ក៏ដូចជាឆ្លើយតបទៅនឹងបញ្ហាប្រឈមសំខាន់ៗ ដែលនឹងអាចកើតមាន

ក្នុងឆ្នាំ ២០១៩ វិធានការសម្រាប់អនុវត្តក្នុងឆ្នាំ ២០១៩ (មិនមែនជាវិធានការជាក់លាក់ក្នុងឆ្នាំទេ ប៉ុន្តែ ជាវិធានការប្រចាំគ្រាសំខាន់ៗ) ដែលត្រូវបន្តអនុវត្ត រួមមាន÷

- បង្កើនប្រសិទ្ធភាពនៃដំណើរការរបស់គណៈកម្មាធិការត្រួតពិនិត្យ និងវាយតម្លៃចំណូលមិនមែនសារពើពន្ធ ដើម្បីរៀបចំរបាយការណ៍បូកសរុបជូនប្រមុខរាជរដ្ឋាភិបាលស្តីពីស្ថានភាពនៃការតាមដាន, ការកត់ត្រា និងការប្រមូលចំណូលរបស់ក្រសួង-ស្ថាប័ននៃរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ;
- បង្កើនកិច្ចសហការរវាងថ្នាក់ដឹកនាំ និងមន្ត្រីបង្គោលតាមក្រសួង-ស្ថាប័ន ដែលទទួលខុសត្រូវតាមដាន និងផ្តល់ព័ត៌មាន, កត់ត្រា, កៀរគរចំណូល និងចាត់វិធានការតឹងទារបំណុលឱ្យបានទាន់ពេល ជាមួយយន្តការដែលមានស្រាប់;
- បន្តពង្រឹងការប្រមូលចំណូលមិនមែនសារពើពន្ធឱ្យកាន់តែមានប្រសិទ្ធភាព, តម្លាភាព និងទាន់ពេលវេលា ដោយពង្រឹងការគ្រប់គ្រងស្ថាប័ន, ការទទួលខុសត្រូវ, ការដាក់ទណ្ឌកម្ម, សវនកម្ម និងអធិការកិច្ចតាមរយៈការអនុវត្តបទដ្ឋានគតិយុត្តស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធជាធរមាន;
- បន្តជំរុញ និងលើកទឹកចិត្តឱ្យក្រសួង-ស្ថាប័នប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ដើម្បីសម្រេចបានការធ្វើទំនើបកម្មនៃការកត់ត្រា, ការប្រមូល និងគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ប្រកបដោយប្រសិទ្ធភាព, គណនេយ្យភាព និងទាន់ពេលវេលា;
- បន្តជំរុញការគ្រប់គ្រងសាច់ប្រាក់របស់ក្រសួង-ស្ថាប័ន តាមរយៈប្រព័ន្ធធនាគារក្នុងការបង់ចំណូលចូលថវិកាជាតិ។ ក្រសួង-ស្ថាប័នត្រូវសិក្សាបន្ថែមលើសេវាប្រកួតប្រជែងរបស់បណ្តាធនាគារដៃគូដែលបានចុះអនុស្សារណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីធានាបាននូវប្រសិទ្ធភាពក្នុងការបង់ចំណូល;
- ជំរុញអនុវត្ត និងកែលម្អស្តង់ដារសេវាសម្រាប់បង់ចំណូល ឱ្យមានភាពងាយស្រួល និងតម្លាភាព;
- ពង្រឹងសមត្ថភាពគ្រប់គ្រងវិស័យប្រេង-ឧស្ម័ន ដើម្បីការកៀរគរចំណូលពីវិស័យនេះ;
- ពង្រឹង និងពន្លឿនការអនុវត្តយន្តការដែលបានព្រមព្រៀង និងឯកភាព រួមមាន កម្រៃអាកាសចរស៊ីវិល (CAF), ការបង់កម្រៃលេខទូរគមនាគមន៍, ការបង់កម្រៃពីហ្វ្រេកង់ ព្រមទាំងពន្លឿនការងាររៀបចំកែប្រែកម្រៃអាជ្ញាប័ណ្ណឡើងវិញឱ្យបានគ្រប់ជ្រុងជ្រោយ;
- បន្តពង្រឹងការប្រមូលកម្រៃពីសេវាដឹកអ្នកដំណើរតាមអាកាស ដោយសហការជាមួយបណ្តាស្ថាប័ននានា;
- បន្តបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ច ដោយផ្អែកលើគោលការណ៍របស់រាជរដ្ឋាភិបាល;
- លើកកម្ពស់ប្រសិទ្ធភាពនៃការប្រើប្រាស់និងចាត់ចែងទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធដែលស្ថិតក្រោមការកាន់កាប់របស់ក្រសួង-ស្ថាប័នសាមី ជាពិសេសការធ្វើបច្ចុប្បន្នភាពកិច្ចសន្យា, កិច្ចព្រមព្រៀង និងកិច្ចសន្យាសម្បទាននានា ឱ្យសមស្របតាមស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន និងអនាគត;

- ស្នើគ្រប់ក្រសួង-ស្ថាប័នបន្តកិច្ចសហការល្អ ជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមរយៈការផ្តល់ទិន្នន័យ, កិច្ចព្រមព្រៀង, កិច្ចសន្យា និងឯកសារពាក់ព័ន្ធនានា ដើម្បីបន្តពង្រឹងយន្តការប្រមូលចំណូលឱ្យអស់លទ្ធភាព និងប្រកបដោយប្រសិទ្ធភាព;
- ស្នើអាជ្ញាធរសវនកម្មជាតិពង្រឹងការធ្វើសវនកម្មលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួង-ស្ថាប័ន និងអង្គភាពរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ;
- ពង្រឹង និងពន្លឿនការអនុវត្តបទដ្ឋានគតិយុត្តជាធរមានដែលពាក់ព័ន្ធនឹងកាស៊ីណូ, ល្បែងភ្នាល់, រមណីយដ្ឋានសមាហរណ និងល្បែងពាណិជ្ជកម្មផ្សេងទៀត ដើម្បីកៀរគរចំណូលឱ្យអស់លទ្ធភាព;
- បន្តកិច្ចសហការជាមួយក្រសួងមហាផ្ទៃ ដើម្បីធានាប្រសិទ្ធភាពក្នុងការបង្ក្រាបអាជីវកម្មល្បែងខុសច្បាប់; និង
- អនុវត្តវិធានការផ្សេងទៀត ពាក់ព័ន្ធនឹងផ្នែកចំណូលមិនមែនសារពើពន្ធ ដែលនឹងត្រូវបានដាក់ចេញនៅក្នុងឯកសារយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣។

**ខ. វិធានការផ្នែកចំណាយ**

ដោយឈរលើមូលដ្ឋានការអនុវត្តចំណាយសាធារណៈកន្លងមក និងក្នុងក្របខ័ណ្ឌនៃគោលដៅគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា រាជរដ្ឋាភិបាលចាំបាច់ត្រូវអនុវត្តវិធានការ និងគោលការណ៍ជាក់លាក់មួយចំនួន ដើម្បីបង្កើនប្រសិទ្ធភាពចំណាយក្នុងឆ្នាំ ២០១៩ ដូចខាងក្រោម÷

- បន្តពង្រឹងការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលតាមរយៈការបង្កើនប្រសិទ្ធភាពនៃ÷ (១)- ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា, (២)- ការរៀបចំថវិកា, (៣)- ការវិភាជថវិកា, និង (៤)- ការអនុវត្តថវិកា;
- ពង្រឹងការអនុវត្តថវិកាកម្មវិធីពេញលេញ និងអង្គភាពថវិកានៅគ្រប់ក្រសួង-ស្ថាប័ន ទាំងនៅរដ្ឋបាលកណ្តាល មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល និងពង្រីកការសាកល្បងនៅថ្នាក់ក្រោមជាតិ;
- បន្តអនុវត្តគោលការណ៍បង្កើនបៀវត្សជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ ក្នុងគោលដៅបង្កើនគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ដោយឈរលើគោលការណ៍ប្រសិទ្ធភាព, សមធម៌, សង្គតិភាព, គុណាធិបតេយ្យ និងចីរភាពថវិកា;
- បន្តអនុវត្តគោលការណ៍បង្កើនប្រាក់សោធននិវត្តន៍សម្រាប់អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនព្រមទាំងកាត់បន្ថយគម្លាតរវាងអ្នកចូលនិវត្តចាស់ និងថ្មី;
- បន្តរក្សាអាទិភាព និងវិចារណកម្មនៃគោលនយោបាយចំណាយនៅក្នុងវិស័យអប់រំ, បណ្តុះបណ្តាលវិជ្ជាជីវៈ, ប្រព័ន្ធដឹកជញ្ជូននិងឡជីស្ទីក, និងកសិកម្ម;
- បន្តគាំទ្រការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥;

- បន្តគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ និងទ្រទ្រង់ចីរភាពកំណើនសេដ្ឋកិច្ចសម្រាប់រយៈពេលមធ្យម និងវែង តាមរយៈការបង្កើនចំណាយវិនិយោគសាធារណៈលើការពង្រីក និងពង្រឹងគុណភាពហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា ផ្លូវថ្នល់, ផ្លូវដែក, កំពង់ផែ, ប្រព័ន្ធធារាសាស្ត្រ, អគ្គិសនី និងប្រព័ន្ធទូរគមនាគមន៍ ក្នុងគោលបំណងផ្តល់ភាពងាយស្រួលដល់វិនិយោគិន, ពាណិជ្ជករ និងប្រជាជន;
- បន្តការរឹតត្បិតចំណាយមិនចាំបាច់ ដើម្បីជំរុញការអនុវត្តគោលនយោបាយសំខាន់ៗ និងកម្មវិធីកែទម្រង់ចាំបាច់នានារបស់រាជរដ្ឋាភិបាល;
- ធានាប្រសិទ្ធភាពនៃការវិភាជ និងប្រើប្រាស់ថវិកាសម្រាប់ការថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវន្ត;
- បន្តបង្កើនការវិនិយោគសាធារណៈដើម្បីជំរុញការធ្វើពិពិធកម្ម, ការបង្កើនផលិតភាព និងភាពប្រកួតប្រជែង ក្នុងគោលដៅទ្រទ្រង់កំណើនប្រកបដោយចីរភាព តាមរយៈការធ្វើវិចារណកម្មគោលនយោបាយចំណាយ;
- បន្តជំរុញអនុវត្តកម្មវិធីសាច់ប្រាក់ពលកម្ម (Cash For Work) ដែលជាកម្មវិធីជួយស្តារ និងកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ និងជាកម្មវិធីអន្តរាគមន៍ដោយត្រង់របស់រាជរដ្ឋាភិបាល ក្នុងការបង្កើតការងារនៅទីជនបទ ដែលគាំទ្រដល់វិស័យជំនាញ, ទប់ស្កាត់ការធ្វើចំណាកស្រុក, បង្កើនផលិតភាព និងលើក-កម្ពស់ជីវភាពប្រជាជន នៅទីជនបទ;
- លើកកម្ពស់ប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយ តាមរយៈការបង្កើនតម្លៃនៃលុយ ដោយផ្តោតការ-យកចិត្តទុកដាក់លើភាពសមស្របនៃថ្លៃ, បរិមាណ, គុណភាព និងភាពទាន់ពេលនៃថវិកាដែលបានចំណាយ ទាំងចំណាយចរន្ត និងចំណាយមូលធន;
- ពង្រឹងការគ្រប់គ្រងចំណាយសាធារណៈ និងជំរុញការកែលម្អការអនុវត្តថវិកា តាមរយៈការបន្ត÷ (១)-ការកែសម្រួលនីតិវិធីចំណាយ, (២)-ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់, (៣)-ការពង្រឹងការអនុវត្តកម្មវិធីចំណូល-ចំណាយប្រចាំត្រីមាស, (៤)-ការត្រួតពិនិត្យការអនុវត្តថវិកាប្រចាំត្រីមាស និងឆមាស, (៥)-ការពង្រឹងការត្រួតពិនិត្យផ្ទៃក្នុង ដើម្បីបន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកាដែលសម្រេចបាន និង (៦)-ការបង្កើនប្រសិទ្ធភាពគណនេយ្យភាពហិរញ្ញវត្ថុ និងជំហានបន្ទាប់ផ្សេងៗទៀត;
- លើកកម្ពស់គុណភាពការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ និងអនុលោមភាពនៃការអនុវត្តផែនការនេះដើម្បីធានាឱ្យការរៀបចំថវិកាប្រចាំឆ្នាំឱ្យកាន់តែមានប្រសិទ្ធភាព និងធានាឱ្យការអនុវត្តថវិកាទាន់ពេលវេលាចាប់ពីដើមឆ្នាំ។ ក្នុងន័យនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលដែលស្ថិតក្រោមក្រសួង-ស្ថាប័ននីមួយៗត្រូវរៀបចំសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំសម្រាប់ថវិកាចំណាយដែលត្រូវអនុវត្តនីតិវិធីលទ្ធកម្ម ជាបណ្តើរៗចាប់ពីពេលរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះដោយផ្អែកលើកញ្ចប់ថវិកាដែលគ្រោងស្នើសុំមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បន្ទាប់មកនៅក្នុងពេលលើកសំណើគម្រោងថវិកាឆ្នាំ ២០១៩ ដែលនឹងត្រូវរៀបចំនៅក្នុងអំឡុងខែ មិថុនា និងខែ កក្កដា ឆ្នាំ ២០១៨ ខាងមុខនេះ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល

និងតម្រូវឱ្យភ្ជាប់ផែនការលទ្ធកម្មមកជាមួយនឹងសំណើតម្រោងថវិកាឆ្នាំ ២០១៩ របស់ខ្លួន សម្រាប់ការប្រជុំពិភាក្សា និងចរចាកញ្ចប់ថវិកាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ គោលការណ៍ និងនីតិវិធីនៃការរៀបចំផែនការលទ្ធកម្មត្រូវអនុលោម តាមបទប្បញ្ញត្តិដូចមាន ចែងក្នុងប្រកាសលេខ ៨៥១ សហវ.ប្រក ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៧ ស្តីពីការរៀបចំផែនការលទ្ធកម្ម។

- បន្តគិតគូរឱ្យមានកញ្ចប់ថវិកាត្រៀមបម្រុងសម្រាប់ដោះស្រាយតម្រូវការបន្ទាន់, ករណីតម្រូវការចំណាយចាំបាច់ភ្លាមៗរបស់រាជរដ្ឋាភិបាល, វិបត្តិផ្សេងៗ និងប្រធានស័ក្តិ;
- បន្តអនុវត្តក្របខ័ណ្ឌគោលនយោបាយស្តីពីការគ្រប់គ្រងបំណុលសាធារណៈរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅ រក្សាចីរភាពបំណុលទៅតាមវិធានការគោលនយោបាយគន្លឹះដែលបានគ្រោង រួមមាន÷
  - ពង្រឹងប្រសិទ្ធភាពចំណាយវិនិយោគសាធារណៈ ទាំងក្នុងក្របខ័ណ្ឌហិរញ្ញប្បទានដោយថវិកាជាតិ, ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍, និងទាំងក្នុងក្របខ័ណ្ឌវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន តាមរយៈ÷ (១)-ការរៀបចំអនុក្រឹត្យស្តីពីគោលការណ៍ណែនាំរួមសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈ (PIM), (២)-ការធ្វើបច្ចុប្បន្នកម្មនីតិវិធីរួមសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍, និង (៣)-ការរៀបចំបទដ្ឋានគតិយុត្តសម្រាប់គ្រប់គ្រងគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន (PPP);
  - ធ្វើពិពិធកម្មប្រភពហិរញ្ញប្បទានឱ្យបានទូលំទូលាយជាងមុន តាមរយៈការបន្តកៀរគរហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ក្រោមក្របខ័ណ្ឌនៃយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន និងទីផ្សារមូលបត្រ; និង
- ពង្រឹងការអនុវត្តក្របខ័ណ្ឌគ្រប់គ្រងហានិភ័យបំណុល ជាពិសេសតាមដាន និងត្រួតពិនិត្យហានិភ័យនៃកាតព្វកិច្ចបំណុលជាយថាហេតុដែលអាចកើតចេញពី÷ (១)-ការធានារបស់រដ្ឋលើគម្រោងភាពជាដៃគូរវាងរដ្ឋ និងឯកជន, (២)-វិស័យធនាគារ និងហិរញ្ញវត្ថុ, និង (៣)-ក្រសួង-ស្ថាប័ន, អង្គភាពសាធារណៈប្រហាក់ប្រហែល, គ្រឹះស្ថានសាធារណៈ, សហគ្រាសសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ៣. រចនាសម្ព័ន្ធ និងគោលការណ៍នៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៩-២០២១

ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ បានកំណត់គោលដៅរួមនៃការប្រមូលចំណូល ដោយបានដាក់ចេញនូវវិធានការចាំបាច់ និងជាក់ស្តែងដែលត្រូវអនុវត្តក្នុងឆ្នាំ ដើម្បីសម្រេចគោលដៅទាំងនេះ និងបានកំណត់គោលដៅរួមនៃការអនុវត្តចំណាយ និងដាក់ចេញអាទិភាពគោល-នយោបាយសំខាន់ៗ ដើម្បីសម្រេចគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ដូច្នេះ ក្រសួង-ស្ថាប័ននីមួយៗត្រូវផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដូចបានកំណត់ខាងលើ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ខ្លួន ឱ្យបានល្អត្រឹមត្រូវតាមទិសដៅនេះ និងជាក់ស្តែង។ ទន្ទឹមនេះ ដើម្បីជាមូលដ្ឋានសម្រាប់ក្រសួង-ស្ថាប័ន អាចរៀបចំផែនការយុទ្ធសាស្ត្រថវិកាប្រកបដោយប្រសិទ្ធភាព និងមាន

លក្ខណៈឯកភាពគ្នាទាំងរចនាសម្ព័ន្ធ និងទាំងខ្លឹមសារ ផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំតាមទម្រង់ដូចខាងក្រោម÷

- **ផ្នែកទី១: អំពីសេចក្តីផ្តើម**

ការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៩-២០២១ ត្រូវចាប់ផ្តើមដោយគូសរំលេចអំពីតួនាទី និង បេសកកម្មរបស់ក្រសួង-ស្ថាប័ន, អំពីស្ថានភាពជាក់ស្តែងនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧-២០១៩ និង ការប៉ាន់ស្មានស្ថានភាពនៃការអនុវត្តផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ ធៀបនឹងគោលដៅ សូចនាករដែលបានកំណត់ និងលើកឡើងបញ្ហាប្រឈមដែលត្រូវដោះស្រាយក្នុងឆ្នាំ ២០១៨ និងឆ្នាំខាងមុខ។ បន្ទាប់មកត្រូវបរិយាយរំលេចផងដែរ អំពីវិធានការគោលនយោបាយសំខាន់ៗដែលក្រសួង-ស្ថាប័នបានដាក់ចេញ រួមទាំងគោលនយោបាយតាមវិស័យ និងអន្តរវិស័យ។ **សូមរៀបចំខ្លឹមសារនៃផ្នែកទី ១ នេះ ទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

- **ផ្នែកទី២: អំពីគោលបំណងគោលនយោបាយ**

គោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន ត្រូវបានរៀបចំឡើងសម្រាប់ចក្ខុវិស័យរយៈពេលមធ្យម និងវែង (៣-៥ឆ្នាំ) ដោយផ្អែកលើគោលនយោបាយតាមវិស័យ និងអន្តរវិស័យ ដែលចែងក្នុងយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ គោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ មិនមែនជាកម្មវត្ថុនៃការធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំនោះទេ ប៉ុន្តែក្រសួង-ស្ថាប័នខ្លះ គួរពិនិត្យឡើងវិញនូវគោលបំណងគោលនយោបាយដែលបានកំណត់ក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ របស់ខ្លួន ដើម្បីធានាថា គោលនយោបាយដែលបានកំណត់ មានភាពត្រឹមត្រូវ គ្រប់ជ្រុងជ្រោយ និងឆ្លើយតបបានកាន់តែច្បាស់លាស់ទៅនឹងគោលនយោបាយតាមវិស័យរបស់ខ្លួន និងគោលដៅរួមរបស់រាជរដ្ឋាភិបាល។ ទន្ទឹមនេះ សូមបញ្ជាក់ផងដែរថា *ក្រសួង-ស្ថាប័ននីមួយៗត្រូវមានគោលបំណងគោលនយោបាយមិនលើសពីពីរទេ។* **សូមរៀបចំខ្លឹមសារនៃផ្នែកទី ២ នេះទៅតាមទម្រង់គំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

- **ផ្នែកទី៣: អំពីកម្មវិធី**

*ការរៀបចំកម្មវិធី ត្រូវឆ្លើយតបនឹងគោលបំណងគោលនយោបាយដែលបានកំណត់ខាងលើ និងត្រូវពណ៌នាអំពីគោលបំណងនៃកម្មវិធីនីមួយៗឱ្យបានច្បាស់លាស់ ដើម្បីឆ្លុះបញ្ចាំងឱ្យឃើញច្បាស់ថា ការអនុវត្តកម្មវិធីនោះ មានគោលដៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ន។* ដូច្នេះ នៅក្នុងផ្នែកនេះ *គ្រប់ក្រសួង-ស្ថាប័ន និងអង្គភាពថវិកា ត្រូវពិនិត្យឡើងវិញឈ្មោះកម្មវិធី និងកែសម្រួលឱ្យកាន់តែល្អប្រសើរនូវឈ្មោះកម្មវិធីទាំងនោះ ដើម្បីពង្រឹងគុណភាពរចនាសម្ព័ន្ធកម្មវិធីក្នុងគោលបំណងពង្រឹងបន្ថែមទៀតនូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ ក្នុងដំណើរឈានទៅអនុវត្តថវិកាសមិទ្ធកម្មដែលនឹងចាប់អនុវត្តពីឆ្នាំ២០២២។* ជាមួយគ្នានេះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគិតគូរផងដែរដល់ការចូលរួមអនុវត្តការងារដែលមានចរិតជាអន្តរវិស័យ ដូចជា គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម បញ្ហាយេនឌ័រ និងការប្រែប្រួល

អាកាសធាតុ និងផលប៉ះពាល់ពីគ្រោះមហន្តរាយជាដើម។ សូមបញ្ជាក់ផងដែរថា *ក្រសួង-ស្ថាប័ននីមួយៗត្រូវបង្កើតកម្មវិធីមិនឱ្យលើសពី ៥ ឡើយ* ប៉ុន្តែចំពោះអនុកម្មវិធីអាចមានចំនួនសមស្របទៅតាមការចាំបាច់ ដែលបម្រើឱ្យគោលបំណងរួមនៃកម្មវិធីនីមួយៗ។

កម្មវិធី គឺជាឧបករណ៍ដែលបង្កើតឡើង ដើម្បីឱ្យអគ្គនាយកដ្ឋាន/នាយកដ្ឋាន ក្រោមឱវាទរបស់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាលស្ថិតក្រោមក្រសួង-ស្ថាប័នសាមី ដាក់ចេញនូវអនុកម្មវិធី និងចង្កោមសកម្មភាព ព្រមទាំងជាមូលដ្ឋានសម្រាប់ការលើកគម្រោងថវិកាដើម្បីអនុវត្តកម្មវិធីទាំងនោះ ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងផ្នែកទី ២។ គួរកត់សម្គាល់ថា ចង្កោមសកម្មភាពសំដៅលើសកម្មភាពចម្បងៗ ដែលអាចមានចំនួនសមស្របទៅតាមការចាំបាច់សម្រាប់បម្រើឱ្យគោលបំណងរួមនៃអនុកម្មវិធីនីមួយៗ ហើយចង្កោមសកម្មភាពមួយ អាចមានសកម្មភាពតូចៗមួយចំនួនដែលរួមចំណែកបង្កើតធាតុចេញ (Output) សម្រាប់ចង្កោមសកម្មភាពនោះ ។

កម្មវិធី ត្រូវមានខ្លឹមសារទូលាយ និងមានលក្ខណៈគ្របដណ្តប់បានទាំងស្រុង គ្រប់តួនាទីភារកិច្ច និងបេសកកម្មរបស់ក្រសួង-ស្ថាប័ននីមួយៗ ព្រមទាំងមានលក្ខណៈសមាហរណកម្ម ដោយត្រូវគ្របដណ្តប់លើគម្រោង ឬ សកម្មភាពការងារទាំងអស់ ទាំងគម្រោង ឬសកម្មភាពការងារដែលហិរញ្ញប្បទានដោយថវិការដ្ឋ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការ ទាំងថវិកាចរន្ត និងថវិកាមូលធន។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័ន ត្រូវកំណត់អង្គភាពទទួលខុសត្រូវ ដែលហៅថា **អង្គភាពថវិកា** និងអ្នកគ្រប់គ្រងទៅតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធី (កម្មវិធី អនុកម្មវិធី និង ចង្កោមសកម្មភាព)។

ទន្ទឹមនេះ ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ប្រព័ន្ធថវិកា ក្រសួង-ស្ថាប័ននីមួយៗ ត្រូវកំណត់ភារកិច្ច វិសាលភាពការងារ និងក្របខ័ណ្ឌទទួលខុសត្រូវរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងមន្ទីរជំនាញរាជធានី-ខេត្តឱ្យច្បាស់លាស់នៅក្នុងរចនាសម្ព័ន្ធកម្មវិធី។ មន្ទីរជំនាញរាជធានី-ខេត្ត មិនចាំបាច់ត្រូវមានកម្មវិធីដោយឡែកទេ ព្រោះមន្ទីរជំនាញរាជធានី-ខេត្ត គឺជាដៃ ឬខ្សែបណ្តោយរបស់ក្រសួង នៅតាមរាជធានី-ខេត្ត ដែលមានភារកិច្ចចូលរួមចំណែកអនុវត្តបណ្តាកម្មវិធីរបស់ក្រសួង-ស្ថាប័ន។

ក្នុងន័យនេះ **ក្រសួង-ស្ថាប័ននីមួយៗ ត្រូវណែនាំមន្ទីរជំនាញនៅរាជធានី-ខេត្តរៀងៗខ្លួន អំពីអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីនីមួយៗ ដោយផ្អែកលើមុខងារ វិសាលភាពការងារ និងលក្ខណៈដោយឡែកនៃគោលនយោបាយ និងសេវាសាធារណៈរបស់ក្រសួង-ស្ថាប័នរៀងៗខ្លួន ដើម្បីឱ្យមន្ទីរជំនាញរាជធានី-ខេត្ត របស់ខ្លួនដឹងច្បាស់អំពីទីតាំងនៃអនុកម្មវិធីរួមមួយនៅក្នុងកម្មវិធីនីមួយៗរបស់ក្រសួង-ស្ថាប័នរៀងៗខ្លួន។ ជាទូទៅ មន្ទីរជំនាញមួយអាចមានចង្កោមសកម្មភាពគាំទ្រគ្រប់កម្មវិធីរបស់ក្រសួង-ស្ថាប័ន ឬអាចមានចង្កោមសកម្មភាពគាំទ្រ ២ ទៅ ៣ ដោយផ្អែកតាមមុខងារ និងភារកិច្ចរបស់មន្ទីរជំនាញរាជធានី-ខេត្តនៃក្រសួង-ស្ថាប័ននីមួយៗ។** ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល **ត្រូវរៀបចំផ្នែកទី ៣ នេះ ទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

- **ផ្នែកទី៤: សូចនាករ និងគោលដៅសូចនាករ នៃសមិទ្ធកម្ម ឬ លទ្ធផល**

គោលបំណងគោលនយោបាយ កម្មវិធី និងអនុកម្មវិធីមួយៗ ត្រូវមានសូចនាករ (Indicator) សម្រាប់វាស់វែងលទ្ធផល ឬ សមិទ្ធកម្ម ហើយត្រូវកំណត់គោលដៅ (Target) សូចនាករលទ្ធផលដែលចង់សម្រេចបានសម្រាប់ជាមូលដ្ឋាន នៃការត្រួតពិនិត្យតាមដាន និងវាយតម្លៃលទ្ធផលនៃការអនុវត្ត។ ក្នុងការកំណត់សូចនាករសម្រាប់ការវាស់វែង ក្រសួង-ស្ថាប័ននីមួយៗ ត្រូវកំណត់ទាំងសូចនាករលទ្ធផលក្នុងឆ្នាំ (Output) និងលទ្ធផលចុងក្រោយ (Outcome)។

សូចនាករលទ្ធផលក្នុងឆ្នាំ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់លទ្ធផល/សមិទ្ធកម្មនៃការអនុវត្តកម្មវិធី អនុកម្មវិធី ចង្កោមសកម្មភាព ទៅតាមគោលដៅដែលបានកំណត់ក្នុងរយៈពេលជាក់លាក់មួយដែលមិនលើសពីមួយឆ្នាំ។ រីឯសូចនាករលទ្ធផលចុងក្រោយ គឺជារង្វាស់ដែលបានជ្រើសរើសសម្រាប់វាស់លទ្ធផល/សមិទ្ធកម្មចុងក្រោយនៃកម្មវិធី។

ក្រសួង-ស្ថាប័ននីមួយៗ អាចកែលម្អសូចនាករតាមកម្រិតនៃរចនាសម្ព័ន្ធកម្មវិធីនីមួយៗ តាមរយៈការបន្ថែមសូចនាករថ្មី និងកែសម្រួលសូចនាករចាស់ដែលបានកំណត់កន្លងមក។ ការជ្រើសរើសសូចនាករនីមួយៗ ត្រូវមានការពន្យល់ពីមូលហេតុឱ្យច្បាស់លាស់។ ចំពោះសូចនាករចាស់ ត្រូវបញ្ជាក់អំពីស្ថានភាពនៃការអនុវត្តឆ្នាំ ២០១៧ ការព្យាករស្ថានភាពនៃការអនុវត្តក្នុងឆ្នាំ ២០១៨ និងធ្វើបច្ចុប្បន្នភាពតាមការជាក់ស្តែង។

**កម្មវិធីនីមួយៗ អាចមានសូចនាករលទ្ធផលចុងក្រោយយ៉ាងច្រើនចំនួន ៣ និងសូចនាករលទ្ធផលក្នុងឆ្នាំមួយចំនួន** ដើម្បីធានានូវការសម្រេចបានលទ្ធផលជាក់លាក់នៃការអនុវត្តកម្មវិធី។ ជារួម បន្ទាប់ពីការជ្រើសរើស និងកំណត់បាននូវសូចនាករសមស្របរួចហើយ ចាំបាច់ត្រូវកំណត់គោលដៅនៃសូចនាករ ទាំងគោលដៅសូចនាករលទ្ធផលក្នុងឆ្នាំ និងគោលដៅសូចនាករលទ្ធផលចុងក្រោយ។ គោលដៅសូចនាករទាំងពីរប្រភេទនេះចាំបាច់ត្រូវឱ្យមានទំនាក់ទំនងគ្នា និងឆ្លើយតបគ្នាយ៉ាងមានប្រសិទ្ធភាព ដើម្បីធានានូវការសម្រេចបានលទ្ធផលនៃគោលបំណងគោលនយោបាយដែលបានកំណត់នៅក្នុងរយៈពេលជាក់លាក់មួយ។ គោលដៅសូចនាករលទ្ធផលក្នុងឆ្នាំមានលក្ខណៈជាបរិមាណ ឬ/និងជាគុណភាពប្រចាំឆ្នាំ ដែលជាសមិទ្ធកម្មនៃការអនុវត្ត កម្មវិធីនីមួយៗ។ រីឯគោលដៅសូចនាករលទ្ធផលចុងក្រោយ គឺជាគោលដៅសមិទ្ធកម្មចុងក្រោយជាបរិមាណឬ/និងជាគុណភាព ដែលជាលទ្ធផលបង្កើតឡើងដោយលទ្ធផលក្នុងឆ្នាំនៃការអនុវត្តកម្មវិធី នៅក្នុងរយៈពេល មធ្យមនិងវែង (លើសពី១ឆ្នាំ)។ ក្នុងការកំណត់គោលដៅសូចនាករ កត្តាចាំបាច់និងសំខាន់បំផុត គឺត្រូវដឹងអំពីស្ថានភាពបច្ចុប្បន្នរបស់សូចនាករទាំងនោះ ទើបអាចទៅកំណត់គោលដៅដែលចង់បាន ដើម្បីឱ្យឆ្លើយតបបាន ទៅនឹងគោលបំណងគោលនយោបាយដែលបានកំណត់ ហើយការកំណត់គោលដៅនេះ ចាំបាច់ត្រូវតែមាន ភាពសមស្របនិងប្រាកដនិយមដែលអាចអនុវត្តបាន។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល **ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៤ នេះ ទៅតាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

- **ផ្នែកទី៥: ការកំណត់ធនធានថវិកា**

ក្រសួង-ស្ថាប័ននីមួយៗ ត្រូវគ្រោងទាំងធនធានថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់

អនុវត្តកម្មវិធី សម្រាប់រយៈពេលបីឆ្នាំរំកិល ២០១៩-២០២១។

**ក-ការគ្រោងចំណូល**

ការគ្រោងចំណូល គឺជាការគ្រោងសម្រាប់រយៈពេល ៣ ឆ្នាំ ២០១៩-២០២១ ដោយរួមទាំងចំណូលថវិការដ្ឋដែលស្ថិតក្រោមការគ្រប់គ្រង និងប្រមូលផ្ទាល់ដោយក្រសួង-ស្ថាប័ន និងចំណូលដែលបានមកពីហិរញ្ញប្បទានសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍ និង ប្រភពផ្សេងៗទៀត។ នៅក្នុងការគ្រោងចំណូល ក្រសួង-ស្ថាប័ន ដោយរួមទាំងមន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវផ្ដោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម÷

- គោលដៅសូចនាករចំណូលនៃក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលបានដាក់ចេញនៅក្នុងសារាចរនេះ
- ការវាយតម្លៃការអនុវត្តការប្រមូលចំណូលក្នុងឆ្នាំកន្លងទៅ និងការប៉ាន់ស្មានការអនុវត្តប្រមូលចំណូលក្នុងឆ្នាំកំពុងអនុវត្ត
- ការដាក់ចេញវិធានការជាក់ស្ដែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ ដើម្បីបង្កើនការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។

ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំផ្នែកនេះទៅតាម **តារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។** នៅក្នុងផ្នែកនេះ ប្រសិនបើក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ដែលមិនមានប្រភពចំណូល គឺពុំតម្រូវឱ្យរៀបចំឡើយ ។

ទន្ទឹមនេះ ក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត ព្រមទាំងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានប្រភពចំណូល គឺត្រូវរៀបចំដាក់ចេញវិធានការជាក់ស្ដែងបន្ថែមទៀតតាមក្រសួង-ស្ថាប័ននីមួយៗ សម្រាប់ពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូល ដែលស្ថិតនៅក្រោមដែនសមត្ថកិច្ចរបស់ខ្លួន។ *ផ្ទុយទៅវិញ ការគ្រោងចំណូលមិនអស់សក្ដានុពលដែលមាន គឺជាកម្មវត្ថុនៃការរឹតត្បិតចំណាយ នៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់ក្រសួង-ស្ថាប័ន ដែលមានភារកិច្ចប្រមូលចំណូល។*

**ខ-ការគ្រោងចំណាយថវិកា**

ការគ្រោងតម្រូវការចំណាយ គឺជាការគណនាចំណាយសម្រាប់រយៈពេល ៣ ឆ្នាំ ២០១៩-២០២១ ទៅតាមកម្មវិធីនីមួយៗ និងទៅតាមប្រភេទចំណាយ និងប្រភពធនធាន រួមទាំងថវិកាជាតិ និងថវិកាហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍ។ ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរៀបចំខ្លឹមសារនៃផ្នែកទី ៥ នេះ **តាមតារាងគំរូដែលភ្ជាប់ជាមួយសារាចរណែនាំនេះ។**

ក្នុងការគណនាអំពីតម្រូវការថវិកា ដើម្បីអនុវត្តកម្មវិធីនីមួយៗ ត្រូវផ្ដោតការយកចិត្តទុកដាក់លើចំណុចសំខាន់ៗ ដូចខាងក្រោម÷

ទី១-ក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដែលរាជរដ្ឋាភិបាលបានដាក់ចេញ តាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមានគោលដៅសូចនាករម៉ាក្រូ-សេដ្ឋកិច្ចសំខាន់ៗ ដូចជា កំណើនសេដ្ឋកិច្ចប្រចាំឆ្នាំ អត្រាអតិផរណាប្រចាំឆ្នាំ និងគោលដៅសូចនាករចំណាយ ព្រមជាមួយនឹងគោលនយោបាយអាទិភាពចំណាយទាំងផ្នែកចំណាយចរន្ត និង ចំណាយមូលធន ឬ ហៅថា ចំណាយវិនិយោគ,

ទី២-ការវាយតម្លៃអំពីសមត្ថភាពក្នុងការអនុវត្តចំណាយក្នុងរយៈពេលកន្លងមក និងការប៉ាន់ស្មានសមត្ថភាពអនុវត្តចំណាយក្នុងឆ្នាំ ២០១៨ ដែលក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗបាននិងកំពុងអនុវត្ត,

ទី៣-ការកំណត់តម្រូវការថវិកាតាមឆ្នាំនីមួយៗ ត្រូវគណនាចំណាយប្រកបដោយសុក្រឹតភាពទៅតាមតម្រូវការជាក់ស្តែងនៃកម្មវិធីនីមួយៗ ដោយត្រូវគិតគូរឈរលើទិដ្ឋភាពបី ÷

- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានស្រាប់ដែលត្រូវបន្តអនុវត្ត ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័ន រៀងៗខ្លួន,
- ផែនការសកម្មភាព ឬសកម្មភាពការងារដែលមានលក្ខណៈបញ្ចប់ត្រឹមមួយឆ្នាំ, និង
- ផែនការសកម្មភាព ឬសកម្មភាពការងារថ្មី ដើម្បីសម្រេចគោលនយោបាយរបស់ក្រសួង-ស្ថាប័ន រៀងៗខ្លួន។

ដូច្នេះ ផ្អែកលើគោលការណ៍ទាំងបីខាងលើនេះ គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលក្រោមនិវាទទាំងអស់ ត្រូវគ្រោងតម្រូវការចំណាយសម្រាប់ឆ្នាំ ២០១៩-២០២១ តាមគោលការណ៍នៃការកំណត់ពិដានកញ្ចប់ថវិកា ដូចខាងក្រោម÷

- **ចំណាយបន្ទុកបុគ្គលិក** (ជំពូក ៦៤) សម្រាប់គម្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ ២០១៩ ត្រូវគ្រោងតាមមូលដ្ឋាននៃក្របខ័ណ្ឌ និងកម្រិតបៀវត្សឆ្នាំ ២០១៨ គឺតាមតារាងប្រព័ន្ធប្រាក់បៀវត្ស នៃក្រសួងមុខងារសាធារណៈ និងតាមចំនួនមន្ត្រីរាជការដែលមានជាក់ស្តែងក្នុងឆ្នាំ ២០១៨ ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមុខងារសាធារណៈ នឹងចេញគោលការណ៍លម្អិតសម្រាប់ការដំឡើងបៀវត្សមូលដ្ឋាន និងការដំឡើងប្រាក់បំណាច់មុខងាររបស់មន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធសម្រាប់ការរៀបចំ ថវិកាប្រចាំឆ្នាំនាពេលខាងមុខ។
- ដោយឡែក សម្រាប់គម្រោងចំណាយបន្ទុកបុគ្គលិកឆ្នាំ ២០២០ និង ២០២១ ត្រូវគ្រោងក្នុងកម្រិតក្របខ័ណ្ឌ និងកម្រិតបៀវត្សដែលបានគ្រោងសម្រាប់ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ រៀងៗគ្នា ហើយចំនួនក្របខ័ណ្ឌថ្មីយ៉ាងច្រើនត្រូវស្មើនឹងចំនួនមន្ត្រីរាជការដែលចូលនិវត្តន៍ ផ្ទេរចេញ ឬលាឈប់ពីក្របខ័ណ្ឌរដ្ឋ និងមរណភាពដែលត្រូវកាត់ចេញពីអង្គភាពសាមី។
- **ចំណាយក្រៅបន្ទុកបុគ្គលិក** (ជំពូក៦០ ការទិញ, ជំពូក៦១ សេវាកម្ម, ជំពូក៦២ អត្ថប្រយោជន៍សង្គម, ជំពូក៦៥ ឧបត្ថម្ភធន) ជាសរុបសម្រាប់ឆ្នាំ ២០១៩ ត្រូវគ្រោងយ៉ាងច្រើនស្មើនឹងកម្រិត

ឥណទាន អតិបរមានៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៨ ព្រោះអាទិភាពចំណាយឆ្នាំ ២០១៩ ដូចមានចែងក្នុងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ នៅតែផ្តោតជាសំខាន់លើការដំឡើងបៀវត្ស និងការវិនិយោគដើម្បីទ្រទ្រង់កំណើនសេដ្ឋកិច្ច ព្រមទាំងជាមួយគោលនយោបាយពង្រឹងការគ្រប់គ្រងថវិកា (Fiscal Consolidation)។ ***ក្នុងន័យនេះ ក៏មិនមែនមានន័យថា កញ្ចប់ថវិកាឆ្នាំ ២០១៩ នឹងទទួលបានស្មើឆ្នាំ ២០១៨ ដោយស្វ័យប្រវត្តិនោះដែរ*** ព្រោះការគ្រោងចំណាយត្រូវកាត់ចេញមុខចំណាយលើសកម្មភាពការងារដែលត្រូវបានបញ្ចប់ ហើយថវិកាដែលបានកាត់ចេញមិនមែនជាកម្មវត្ថុនៃការវិភាជឡើងវិញនោះទេ លុះត្រាតែផ្តល់ការពន្យល់យ៉ាងត្រឹមត្រូវនិងច្បាស់លាស់សម្រាប់សកម្មភាពការងារចាំបាច់ ឬគោលនយោបាយថ្មី។ ដោយឡែកសម្រាប់ឆ្នាំ ២០២០ និង ២០២១ ការគ្រោងចំណាយចរន្តអាចបង្កើនក្នុងរង្វង់នៃកម្រិតអតិផរណា ធៀបនឹងកញ្ចប់ដែលបានគ្រោងសម្រាប់ឆ្នាំ ២០១៩ និងឆ្នាំ ២០២០ រៀងៗគ្នា។ ហេតុនេះ រាល់ការកំណត់តម្រូវការចំណាយដែលធំ, ថ្មី និង/ឬ ខ្ពស់ជាងគោលការណ៍ដែលបានចែងនេះ គឺត្រូវផ្តល់ឯកសារពាក់ព័ន្ធដែលមានការសិក្សានិងអំណះអំណាងឱ្យបានត្រឹមត្រូវជាក់លាក់ និងច្បាស់លាស់ នៅក្នុងដំណាក់កាលរៀបចំផែនការយុទ្ធសាស្ត្រថវិកានេះឱ្យហើយ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុទើបអាចដាក់ជាកម្មវត្ថុនៃការពិចារណានិងពិភាក្សាចរចានៅពេលរៀបចំកញ្ចប់ថវិកាប្រចាំឆ្នាំបាន។ ជារួម គុណភាពនៃផែនការយុទ្ធសាស្ត្រគឺជាកម្មវត្ថុនៃការរឹតត្បិត ឬលើកទឹកចិត្តចំណាយនៅក្នុងដំណាក់កាលចរចាកញ្ចប់ថវិកាប្រចាំឆ្នាំសម្រាប់គ្រប់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និង គ្រឹះស្ថានសាធារណៈរដ្ឋបាល។

- **ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានថវិកាជាតិ** (ជំពូក២១) សម្រាប់ក្រសួងសាធារណការនិងដឹកជញ្ជូន, ក្រសួងអភិវឌ្ឍន៍ជនបទ, និង ក្រសួងធនធានទឹកនិងឧតុនិយម ត្រូវបន្តអនុវត្តតាមយន្តការគណៈកម្មការអន្តរក្រសួង ក្នុងការកំណត់អាទិភាពគម្រោង និងទំហំថវិកាសម្រាប់ឆ្នាំ ២០១៩ ដែលមានទំហំប្រហាក់ប្រហែលនឹងឆ្នាំ ២០១៨។ ដោយឡែក ក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀតដែលមានតម្រូវការចំណាយវិនិយោគ ត្រូវសិក្សានិងលើកគម្រោងក្នុងកម្រិតទំហំថវិកាសមស្រប ដើម្បីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំអាទិភាពភារូបនីយកម្មគោរពសុំការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ទៅតាមលទ្ធភាពថវិកាក្នុងទំហំដ៏សមស្រប ប៉ុន្តែជាក់ស្តែង គឺអាស្រ័យលើលទ្ធភាពនៃថវិកាក្នុងដំណាក់កាលរៀបចំថវិកាប្រចាំឆ្នាំ។
- **ចំណាយមូលធន/វិនិយោគដោយហិរញ្ញប្បទានសហប្រតិបត្តិការដោយដៃគូអភិវឌ្ឍន៍** ក្រសួង-ស្ថាប័នដែលបាន និងកំពុងទទួលបានហិរញ្ញប្បទានសហប្រតិបត្តិការ ឬគ្រោងនឹងទទួលបានហិរញ្ញប្បទានស្របតាមកម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល (២០១៩-២០២១) ត្រូវគ្រោងឱ្យបានត្រឹមត្រូវទៅតាមកិច្ចព្រមព្រៀង ឬ អនុស្សារណៈនៃការយោគយល់គ្នា ឬ ការសន្យាតាមរយៈយន្តការផ្សេងៗ។

- **ផ្នែកទី៦: សេចក្តីសន្និដ្ឋាន**

ផ្នែកចុងក្រោយ គឺជាការសន្និដ្ឋានទៅលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៩-២០២១ និង

ការលើកទិសដៅ និងវិធានការ ដើម្បីសម្រេចគោលដៅដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៩-២០២១។

## ៤. សេចក្តីសន្និដ្ឋាន

ផែនការយុទ្ធសាស្ត្រថវិកា គឺជាយន្តការមួយនៃដំណើការរៀបចំថវិកាប្រចាំឆ្នាំ ដែលបានដាក់ឱ្យអនុវត្តក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ដែលក្រសួង-ស្ថាប័ននីមួយៗ ត្រូវរៀបចំឱ្យបានច្បាស់លាស់ ត្រឹមត្រូវ មានតម្លាភាព និង មានគណនេយ្យភាព ដើម្បីអនុវត្តកម្មវិធី ក្នុងគោលដៅសម្រេចគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័នរៀងៗខ្លួន និង ដើម្បីចូលរួមចំណែកសម្រេចគោលនយោបាយរបស់រាជរដ្ឋាភិបាល។ ការរៀបចំផែនការយុទ្ធសាស្ត្រថវិកា គឺជាដំណាក់កាលទី ១ នៃដំណើរការរៀបចំថវិកាប្រចាំឆ្នាំ ដែលក្រសួង-ស្ថាប័ននីមួយៗ មានលទ្ធភាពគ្រោងផែនការថវិកាសម្រាប់អនុវត្តកម្មវិធី ដោយផ្អែកលើក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈ ដើម្បីបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ។

ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ក្នុងក្របខ័ណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាវិធានការសំខាន់សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃការរៀបចំថវិកា និង ការបែងចែកធនធានថវិកា។ ជាវិធីសាស្ត្រជាក់ស្តែងមួយ ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៩-២០២១ ឱ្យបានសមស្រប ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលនីមួយៗ ត្រូវត្រួតពិនិត្យឡើងវិញ និងវាយតម្លៃការអនុវត្តកន្លងមក ដោយផ្អែកលើផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៨-២០២០ របស់ខ្លួន ហើយរៀបចំកែសម្រួលទៅតាមការណែនាំនៃសារាចរនេះ។

*គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាសម្រាប់ឆ្នាំ២០១៩-២០២១ ដែលមានវិសាលភាពគ្របដណ្តប់ទាំងផែនការយុទ្ធសាស្ត្រថវិការបស់មន្ទីរជំនាញរាជធានី-ខេត្ត និងរបស់គ្រឹះស្ថានសាធារណៈរដ្ឋបាល មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៨* ដើម្បីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុមានពេលវេលាគ្រប់គ្រាន់សម្រាប់ពិនិត្យនិងបូកសរុប និងស្នើសុំការបំភ្លឺបន្ថែមតាមការចាំបាច់ពីក្រសួង-ស្ថាប័ន និងមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។ ដើម្បីសម្រួលដល់ដំណើរការ ពិនិត្យនិងបូកសរុបផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង-ស្ថាប័ននីមួយៗ *មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវបញ្ជូនផែនការយុទ្ធសាស្ត្រថវិកាមួយច្បាប់ទៅក្រសួង-ស្ថាប័នសាមី និងមួយច្បាប់មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (នាយកដ្ឋានថវិកានីយកម្មនៃអគ្គនាយកដ្ឋានថវិកា) តាមពេលវេលា ដែលបានកំណត់ខាងលើ។* ប្រសិនបើក្រសួង-ស្ថាប័នមិនបានផ្តល់ផែនការយុទ្ធសាស្ត្រថវិកា តាមពេលវេលាកំណត់ខាងលើ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបានអនុញ្ញាតឱ្យស្នើការវិភាជកញ្ចប់ថវិកាប្រចាំឆ្នាំ ដោយផ្អែកលើមូលដ្ឋាននៃផែនការយុទ្ធសាស្ត្រថវិកាឆ្នាំចាស់ និងការអនុវត្តថវិកានៃឆ្នាំកន្លងទៅ។

ទទួលបានសារាចរណែនាំនេះ ក្រសួង-ស្ថាប័ន រួមទាំងមន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាលទាំងអស់ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងឱ្យបានទាន់ឱសានវាទ។ ក្នុងករណីក្រសួង-ស្ថាប័ន និង

មន្ទីរជំនាញរាជធានី-ខេត្ត និងគ្រឹះស្ថានសាធារណៈរដ្ឋបាល មានចំណុចណាមួយមិនច្បាស់លាស់ខាងផ្នែកបច្ចេកទេសរៀបចំ ត្រូវទាក់ទងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានថវិកា) ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៩-២០២១ ឱ្យបានទាន់ពេលវេលាតាមកាលកំណត់ **និងផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យបានមុនថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៨។**

ថ្ងៃចន្ទ ៩ រោច ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមេសា ឆ្នាំ២០១៨

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

"ដើម្បីជូនជ្រាប"

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-រាជកិច្ច "ដើម្បីចុះផ្សាយ"

-គ្រប់ក្រសួង-ស្ថាប័ន

-គ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល

-គ្រប់អភិបាលនៃគណៈអភិបាលរាជធានី-ខេត្ត

-គ្រប់មន្ទីរជំនាញរាជធានី-ខេត្ត

"ដើម្បីមុខការ"

-ឯកសារ-កាលប្បវត្តិ

# ផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៩-២០២១

# ក្រសួង ស្ថាប័ន .....................

## I. សេចក្តីផ្តើម

.....................................................................................................

១. រំលេចអំពីបេសកកម្ម និងភារកិច្ចចម្បងៗសម្រាប់ឆ្នាំ ២០១៩-២០២១ ក្នុងក្របខ័ណ្ឌនៃតួនាទី និងភារកិច្ចរបស់ក្រសួង ស្ថាប័ន

.....................................................................................................

.....................................................................................................

.....................................................................................................

២. បរិយាយអំពីលទ្ធផលសម្រេចបានក្នុងឆ្នាំ ២០១៧ (ធៀបសូចនាករដែលបានកំណត់)

.....................................................................................................

.....................................................................................................

.....................................................................................................

៣. លើកអំពីបញ្ហាប្រឈម (ដែលត្រូវយកចិត្តទុកដាក់ក្នុងឆ្នាំ ២០១៨ និង ឆ្នាំខាងមុខ)

.....................................................................................................

.....................................................................................................

.....................................................................................................

៤.លើកអំពីវិធានការគោលនយោបាយសម្រាប់រួមចំណែកអនុវត្តអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាល និងវិធានការគោលនយោបាយដែលមានចរិតតាមវិស័យ និងអន្តរវិស័យសម្រាប់ឆ្នាំ ២០១៩-២០២១

.....................................................................................................

.....................................................................................................

.....................................................................................................

.....................................................................................................

.....................................................................................................

## II. គោលបំណងគោលនយោបាយ

ដើម្បីរួមចំណែកអនុវត្តគោលនយោបាយតាមវិស័យ ពិសេស **គោលនយោបាយរួមរបស់រាជរដ្ឋាភិបាល** ដើម្បី **កំណើន ការងារ សមធម៌** និង**ប្រសិទ្ធភាព** សំដៅសម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់កម្រិតជីវភាពរបស់ប្រជាពលរដ្ឋ ក្រសួង ស្ថាប័ន.......................... មានគោលបំណងគោលនយោបាយដូចខាងក្រោមៈ

| គោលបំណងគោលនយោបាយ | បម្រើឱ្យគោលដៅយុទ្ធសាស្ត្រណាមួយ និងវិធានការគោលនយោបាយអ្វីខ្លះរបស់រាជរដ្ឋាភិបាល | ស្ថិតនៅក្នុងវិស័យណាមួយនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
|---|---|---|
| ទី១ : ........................................ | | |
| ទី២ : ........................................ | | |

<u>**កំណត់សំគាល់**</u> ÷ តារាងខាងលើនេះ ផ្តល់ជាគំនិតថា គោលបំណងគោលនយោបាយដែលត្រូវកំណត់ត្រូវធ្វើយ៉ាងណាឱ្យមានខ្លឹមសារឆ្លើយទៅនឹងចំណុចគោលក្នុងតារាងនេះបាន។ ហេតុនេះក្រសួង ស្ថាប័ន អាចរៀបចំមកវិញជាទម្រង់តារាងសង្ខេបបែបនេះក៏បាន ឬ ក៏រៀបចំជាខ្លឹមសារអធិប្បាយពន្យល់អំពីគោលបំណងគោលនយោបាយ ដោយមិនបាច់ជាទម្រង់តារាងខាងលើនេះក៏បាន។ សំខាន់គឺធ្វើយ៉ាងណាឱ្យតែអាចឆ្លុះបញ្ចាញអំពីភាពច្បាស់លាស់ និងសារៈសំខាន់នៃគោលនយោបាយកាន់តែប្រសើរ។

## III. ការរៀបចំកម្មវិធី

ដើម្បីអនុវត្តគោលបំណងគោលនយោបាយខាងលើឱ្យទទួលបានជោគជ័យ ក្រសួង ស្ថាប័ន បានរៀបចំ **កម្មវិធី** ចំនួន ........(មិនលើសពី ៥) ដូចខាងក្រោម÷

១- ..........................................................................................

គោលបំណងនៃកម្មវិធី÷ .........

២- ..........................................................................................

គោលបំណងនៃកម្មវិធី÷ .........

៣- ..........................................................................................

គោលបំណងនៃកម្មវិធី÷ .........

<u>*កំណត់សំគាល់*</u>÷ត្រូវបរិយាយអំពីគោលបំណងរបស់កម្មវិធី/អនុកម្មវិធីនីមួយៗ ដើម្បីងាយស្រួលក្នុងការកំណត់សូចនាករ និងគោលដៅសូចនាករ។

ក្រសួង ស្ថាប័ន ........................

| តារាង ១ : កម្មវិធី អនុកម្មវិធី អ្នកគ្រប់គ្រង និង អង្គភាពទទួលខុសត្រូវ | | | |
|---|---|---|---|
| ឈ្មោះ<br>គោលបំណងគោលនយោបាយ | ឈ្មោះ កម្មវិធី និង អនុកម្មវិធី | អ្នកគ្រប់គ្រង | អង្គភាពទទួលខុសត្រូវ |
| ○ គោលបំណងគ.ប.ទី១ :............... | ▪ កម្មវិធីទី១ : ...............................................<br>• អនុកម្មវិធីទី១ : ....................................<br>• អនុកម្មវិធីទី.... : .................................... | | |
| | ▪ កម្មវិធីទី២ : ...............................................<br>• អនុកម្មវិធីទី១ : ....................................<br>• អនុកម្មវិធីទី.... : .................................... | | |
| ○ គោលបំណងគ.ប.ទី២ :............... | ▪ កម្មវិធីទី៣ : ...............................................<br>• អនុកម្មវិធីទី១ : ....................................<br>• អនុកម្មវិធីទី.... : .................................... | | |
| | ▪ ....................: ............................................... | | |

(*) *ជាគោលការណ៍ ចំនួនគោលបំណងគោលនយោបាយ មិនត្រូវមានលើសពី ២ ឡើយ*

(**) *ជាគោលការណ៍ ចំនួនកម្មវិធី មិនត្រូវមានលើសពី ៥ ឡើយ*

## IV. ការកំណត់សូចនាករ និងគោលដៅសូចនាករ

ក្រសួង ស្ថាប័ន.......................................បានកំណត់នូវសូចនាករនិងគោលដៅសូចនាករ ដើម្បីតាមដានវឌ្ឍនភាពនិងសមិទ្ធផលនៃការអនុវត្តកម្មវិធី អនុកម្មវិធី និងគោលបំណងគោលនយោបាយនីមួយៗដូចខាងក្រោម ÷

ក្រសួង ស្ថាប័ន.......................................................

**តារាង ២ : ការកំណត់សូចនាករ និង គោលដៅសូចនាករ នៃកម្មវិធី និង អនុកម្មវិធី**

| ឈ្មោះ គោលបំណងគោលនយោបាយ កម្មវិធី និងអនុកម្មវិធី | សូចនាករលទ្ធផលក្នុងឆ្នាំ និង គោលដៅ | | | | សូចនាករលទ្ធផលចុងក្រោយ និងគោលដៅ(*) | |
|---|---|---|---|---|---|---|
| | សូចនាករ | ឆ្នាំ២០១៧ (អនុវត្ត) | ឆ្នាំ២០១៨ (បច្ចុប្បន្ន) | ឆ្នាំ២០១៩ (គ្រោង) | សូចនាករ | គោលដៅ |
| o គោលបំណងគ.ប.ទី១ :..................... | | | | | | |
| ▪ កម្មវិធីទី១ :.................................. | | | | | | |
| ✓ អនុកម្មវិធីទី១:............................. | | | | | | |
| ▪ កម្មវិធីទី២ :.................................. | | | | | | |
| ✓ អនុកម្មវិធីទី១:............................. | | | | | | |
| o គោលបំណងគ.ប.ទី២ :..................... | | | | | | |
| ▪ កម្មវិធីទី៣ :.................................. | | | | | | |
| ✓ អនុកម្មវិធីទី១:............................. | | | | | | |

(*) *កម្មវិធីនីមួយៗ អាចមានសូចនាករលទ្ធផលចុងក្រោយយ៉ាងច្រើនចំនួន ៣*

## V. ការកំណត់ធនធាន

### ក. ការគ្រោងចំណូល

ដើម្បីរួមចំណែកការអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ ២០១៩-២០២៣ របស់រាជរដ្ឋាភិបាល និងដើម្បីចូលរួមសម្រេចឱ្យបានគោលដៅសូចនាករចំណូល ដែលបានកំណត់ក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៩-២០២១ ក្រសួង ស្ថាប័ន................. បានដាក់ចេញនូវវិធានការមួយចំនួន ដើម្បីពង្រឹងការប្រមូលចំណូលដូចខាងក្រោម÷

ក..................................................

ខ..................................................

..................................................

តាមរយៈវិធានការទាំងនេះ ក្រសួង ស្ថាប័ន.......................................... បានគ្រោងចំណូលដូចខាងក្រោម÷

ក្រសួង ស្ថាប័ន..................................................

**តារាង ៣ : ការគ្រោងចំណូល**

ឯកតា : លានរៀល

| ការគ្រោងចំណូល តាមប្រភេទចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៨ | | | គ្រោងឆ្នាំ២០១៩ | | | គ្រោងឆ្នាំ២០២០ | | | គ្រោងឆ្នាំ២០២១ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ |
| សរុបរួម | | | | | | | | | | | | |
| ១. ចំណូលពីប្រភពក្នុងស្រុក<br>⌖ ចំណូលសារពើពន្ធ<br>⌖ ចំណូលមិនមែនសារពើពន្ធ | | | | | | | | | | | | |

**តារាង ៣ : ការគ្រោងចំណូល**

ឯកតា : លានរៀល

| ការគ្រោងចំណូល តាមប្រភេទចំណូល | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៨ | | | គ្រោងឆ្នាំ២០១៩ | | | គ្រោងឆ្នាំ២០២០ | | | គ្រោងឆ្នាំ២០២១ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ |
| ⌖ ចំណូលមូលធនក្នុងស្រុក (ការខ្ចីបន្ត) | | | | | | | | | | | | |
| ២. ចំណូលពីការអនុវត្តគម្រោង<br>- គម្រោងវិនិយោគ (មានហិរញ្ញប្បទាន)<br>⌖ គម្រោង......................................<br>⌖ គម្រោង......................................<br>- ជំនួយបច្ចេកទេស (មានហិរញ្ញប្បទាន)<br>⌖ គម្រោង......................................<br>⌖ គម្រោង...................................... | | | | | | | | | | | | |

## ២. ការកំណត់តម្រូវការចំណាយ

ក្រសួង ស្ថាប័ន.....................................................

**តារាង ៤ : ការកំណត់តម្រូវការចំណាយសម្រាប់កម្មវិធី និងអនុកម្មវិធី**

ឯកតា : លានរៀល

| តម្រូវការឥណទាន តាមប្រភេទចំណាយ | ច្បាប់ហិរញ្ញវត្ថុ ឆ្នាំ២០១៨ | | | គ្រោងតម្រូវការឥណទាន សម្រាប់ឆ្នាំ២០១៩ | | | គ្រោងតម្រូវការឥណទាន សម្រាប់ឆ្នាំ២០២០ | | | គ្រោងតម្រូវការឥណទាន សម្រាប់ឆ្នាំ២០២១ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ |
| **សរុបរួម** | | | | | | | | | | | | |
| ▫ សរុបចំណាយចរន្ត | | | | | | | | | | | | |
| ◈ បន្ទុកបុគ្គលិក | | | | | | | | | | | | |
| ◈ ក្រៅបន្ទុកបុគ្គលិក | | | | | | | | | | | | |
| ▫ សរុបចំណាយមូលធន | | | | | | | | | | | | |
| ◈ គម្រោងវិនិយោគ | | | | | | | | | | | | |
| - មានហិរញ្ញប្បទាន | | | | | | | | | | | | |
| - មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| ◈ ជំនួយបច្ចេកទេស | | | | | | | | | | | | |
| - មានហិរញ្ញប្បទាន | | | | | | | | | | | | |
| - មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |

**តារាង ៤ : ការកំណត់តម្រូវការចំណាយសម្រាប់កម្មវិធី និងអនុកម្មវិធី**

ឯកតា : លានរៀល

| តម្រូវការឥណទានតាមប្រភេទចំណាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨ | | | គ្រោងតម្រូវការឥណទានសម្រាប់ឆ្នាំ២០១៩ | | | គ្រោងតម្រូវការឥណទានសម្រាប់ឆ្នាំ២០២០ | | | គ្រោងតម្រូវការឥណទានសម្រាប់ឆ្នាំ២០២១ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ |
| ១. គោលបំណងគោលនយោបាយទី១<br>▫ សរុបចំណាយចរន្ត<br>⌖ បន្ទុកបុគ្គលិក<br>⌖ ក្រៅបន្ទុកបុគ្គលិក<br>▫ សរុបចំណាយមូលធន<br>⌖ គម្រោងវិនិយោគ<br>- មានហិរញ្ញប្បទាន<br>- មិនទាន់មានហិរញ្ញប្បទាន<br>⌖ ជំនួយបច្ចេកទេស<br>- មានហិរញ្ញប្បទាន<br>- មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| ១.១. : កម្មវិធីទី១<br>▫ សរុបចំណាយចរន្ត<br>⌖ បន្ទុកបុគ្គលិក<br>⌖ ក្រៅបន្ទុកបុគ្គលិក<br>▫ សរុបចំណាយមូលធន<br>⌖ គម្រោងវិនិយោគ<br>- មានហិរញ្ញប្បទាន<br>- មិនទាន់មានហិរញ្ញប្បទាន<br>⌖ ជំនួយបច្ចេកទេស<br>- មានហិរញ្ញប្បទាន | | | | | | | | | | | | |

**តារាង ៤ : ការកំណត់តម្រូវការចំណាយសម្រាប់កម្មវិធី និងអនុកម្មវិធី**

ឯកតា : លានរៀល

| តម្រូវការឥណទានតាមប្រភេទចំណាយ | ច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៨ | | | គ្រោងតម្រូវការឥណទានសម្រាប់ឆ្នាំ២០១៩ | | | គ្រោងតម្រូវការឥណទានសម្រាប់ឆ្នាំ២០២០ | | | គ្រោងតម្រូវការឥណទានសម្រាប់ឆ្នាំ២០២១ | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ | ថវិការដ្ឋ | ថវិកាដៃគូអភិវឌ្ឍ | ផ្សេងៗ |
| - មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |
| ១.១.១. : អនុកម្មវិធីទី១<br>▫ សរុបចំណាយចរន្ត<br>⌖ បន្ទុកបុគ្គលិក<br>⌖ ក្រៅបន្ទុកបុគ្គលិក<br>▫ សរុបចំណាយមូលធន<br>⌖ គម្រោងវិនិយោគ<br>- មានហិរញ្ញប្បទាន<br>- មិនទាន់មានហិរញ្ញប្បទាន<br>⌖ ជំនួយបច្ចេកទេស<br>- មានហិរញ្ញប្បទាន<br>- មិនទាន់មានហិរញ្ញប្បទាន | | | | | | | | | | | | |

<u>**កំណត់សំគាល់**</u>

១) **សម្រាប់ចំណាយចរន្ត÷** ជាគោលការណ៍ ការកំណត់តម្រូវការចំណាយត្រូវគិតគូរលើទិដ្ឋភាពបី ÷ ទី១. ផែនការសកម្មភាព ឬសកម្មភាពការងារដែលត្រូវបន្តអនុវត្ត, ទី២. ផែនការសកម្មភាព ឬសកម្មភាពដែលមានលក្ខណៈបញ្ចប់ត្រឹមមួយឆ្នាំ, និង ទី៣. ផែនការសកម្មភាព ឬសកម្មភាពការងារថ្មី។ ហេតុនេះ រាល់ការកំណត់តម្រូវការចំណាយដែលធំ និងខ្ពស់ជាងគោលការណ៍ដែលចែងក្នុងសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (ផ្នែកការគ្រោងចំណាយ) គឺត្រូវផ្តល់ការពន្យល់ និងផ្តល់អំណះអំណាងឱ្យបានត្រឹមត្រូវ ជាក់លាក់ និងច្បាស់លាស់។

២) **សម្រាប់ចំណាយមូលធន ÷**

- គម្រោងមានហិរញ្ញប្បទានសំដៅដល់គម្រោងកំពុងដំណើរការ និងគម្រោងដែលបានចុះកិច្ចសន្យារួច
- គម្រោងមិនទាន់មានហិរញ្ញប្បទានសំដៅដល់គម្រោងកំពុងចរចា និងគម្រោងកំពុងស្វែងរកហិរញ្ញប្បទាន

## VI. **សេចក្តីសន្និដ្ឋាន**

ជាការសន្និដ្ឋានរួម ដោយធ្វើការបូកសរុបសង្ខេបអំពីសារៈសំខាន់នៃផែនការយុទ្ធសាស្ត្រថវិកា ដែលបានរៀបចំ ព្រមជាមួយនឹងការលើកទិសដៅ និងវិធានការដើម្បីសម្រេចគោលដៅដែលបានដាក់ចេញ ..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

រាជធានីភ្នំពេញ ថ្ងៃទី............ខែ................ឆ្នាំ ២០១៨

**រដ្ឋមន្ត្រី/ប្រធានស្ថាប័ន**